វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង

*Working Together for Positive Change*

# សៀវភៅណែនាំស្តីពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងយន្តការសម្របសម្រួលជំនួយនៅកម្ពុជា



រាជធានីភ្នំពេញ កម្ពុជា

ខែមករា ឆ្នាំ២០១២

ការបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស

# សៀវភៅណែនាំស្តីពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងយន្តការសម្របសម្រួលជំនួយនៅកម្ពុជា

**បោះពុម្ពផ្សាយដោយ៖** វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីបញ្ហាអភិវឌ្ឍន៍
គម្រោងគោលនយោបាយអភិវឌ្ឍន៍

**រចនាដោយ៖** **លោក ភួន យូ** មន្ត្រីផ្នែកព័ត៌មាន និងការបោះពុម្ពផ្សាយ

**សេចក្តីបញ្ជាក់៖** ទស្សនៈសម្តែងនៅក្នុងសៀវភៅណែនាំនេះ គឺជាទស្សនៈដែលលើកឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ នៅមុនពេលដែលខ្លឹមសារក្នុងសៀវភៅណែនាំនេះត្រូវបានដកស្រង់ និងបោះពុម្ពឡើងវិញ សូមផ្តល់ការទទួលស្គាល់ក្នុងឯកសារយោង និងធ្វើការស្នើសុំការអនុញ្ញាតជាមុនពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា – ខែមករា ឆ្នាំ ២០១២**

# មាតិកា


- សេចក្តីថ្លែងអំណរគុណ ........ ii
- សេចក្តីសង្ខេប ........ iii

១. សេចក្តីផ្តើម ........ ១

២. ការវិវត្តន៍នៃយន្តការសម្របសម្រួលជំនួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ........ ២

៣. យន្តការបច្ចុប្បន្នសម្រាប់ការពិភាក្សារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ........ ៤

៤. ហេតុអ្វីបានជាអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល គប្បីចូលរួមក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF? ........ ១០

៥. តើអង្គការមិនមែនរដ្ឋាភិបាលចូលរួមយ៉ាងដូចម្តេចឱ្យមានប្រសិទ្ធភាពនៅក្នុងកិច្ចប្រជុំ GDCC និង CDCF? ........ ១៥

៦. ការត្រៀមខ្លួនរបស់ NGO សម្រាប់ការចូលរួមជាយុទ្ធសាស្ត្រនៅក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF ........ ២២

៧. តើអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលវាស់ស្ទង់ប្រសិទ្ធភាព ឬលទ្ធផលនៃការចូលរួមរបស់ខ្លួនយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF? ........ ២៤

៨. ឧបសម្ព័ន្ធ៖ ព័ត៌មានទំនាក់ទំនងនៃតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងក្រុមការងារបច្ចេកទេស (TWGs) ........ ២៦

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំស្តីពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងយន្តការសម្របសម្រួលជំនួយនៅកម្ពុជា ត្រូវបានបោះពុម្ពផ្សាយដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ សៀវភៅណែនាំនេះគឺជាលទ្ធផលរបស់គម្រោងគោលនយោបាយអភិវឌ្ឍន៍ និងគម្រោងប្រសិទ្ធិភាពជំនួយនៃកម្មវិធីបញ្ហាអភិវឌ្ឍន៍។ សៀវភៅណែនាំនេះទទួលបានអត្ថប្រយោជន៍ជាច្រើនពីការគាំទ្រ និងការចង្អុលបង្ហាញពី **លោក ឈិត សំអាត** នាយកប្រតិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ព្រមទាំងការត្រួតពិនិត្យក៏ដូចជាការផ្តល់មតិយោបល់ពី **លោក ផា គីមសុង** ប្រធានគ្រប់គ្រងកម្មវិធីបញ្ហាអភិវឌ្ឍន៍ **លោក ខាំ វ៉ាន់ដា** អ្នកសម្របសម្រួលគម្រោងគោលនយោបាយ និង **លោក តែ ដួងវឌ្ឍនា** អ្នកសម្របសម្រួលគម្រោងប្រសិទ្ធិភាពជំនួយ។ សេចក្តីថ្លែងអំណរគុណនេះ សូមថ្លែងបន្តជូនដល់ **លោក ភួន យូ** នៃមជ្ឈមណ្ឌលនិងស្រាវជ្រាវរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលចំពោះការរចនាដោយផ្ចិតផ្ចង់លើការបោះពុម្ពសៀវភៅនេះ។ សៀវភៅណែនាំនេះ រួមទាំងការបោះពុម្ពផ្សាយដទៃទៀតរបស់កម្មវិធីនឹងមិនអាចចេញផ្សាយទៅបាននោះទេ បើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយ និងដៃគូរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

# សេចក្ដីសង្ខេប

*សៀវភៅណែនាំនេះផ្ដល់នូវទស្សនៈរួមមួយ អំពីរបៀបនិងមូលហេតុដែលអង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងយន្តការបច្ចុប្បន្នសម្រាប់ការពិភាក្សាថ្នាក់ជាតិ និងយន្តការសម្របសម្រួលជំនួយរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន។ យន្តការសម្របសម្រួលជំនួយទាំងឡាយ[១] ដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំនេះរួមមាន៖ វេទិកាសម្រាប់ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (Cambodia Development Cooperation Forum "CDCF") គណៈកម្មាធិ ការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (Government- Development Partners Coordination Committee "GDCC") និងក្រុមការងារបច្ចេកទេស (Technical Working Group "TWG")។* ដូចដែលបានលើកឡើងនៅក្នុងសេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស (២០០៥) ផែនការសកម្មភាពអាក្រា (២០០៨) និង ភាពជាដៃគូទីក្រុងប៊ូសាន ដើម្បីសហប្រតិបត្តិការណ៍អភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិផល (២០១១) ទាំងប្រទេសម្ចាស់ជំនួយ និងប្រទេសជាដៃគូ ឬប្រទេសទទួលជំនួយនានារួមទាំងកម្ពុជា ប្ដេជ្ញាបង្កើនការចូលរួមរបស់ពួកគេជាមួយអង្គការសង្គមស៊ីវិល (CSOs) ឬអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងយន្តការសម្របសម្រួលជំនួយនៅគ្រប់កំរិត ដើម្បីកសាងភាពជាម្ចាស់ចំពោះប្រទេសកម្ពុជា ទៅលើទម្រង់ថ្មីៗនៃការអភិវឌ្ឍន៍របស់ខ្លួន និងទទួលស្គាល់អង្គការសង្គមស៊ីវិលជាតួអង្គអភិវឌ្ឍន៍ឯករាជ្យមួយដែលមានសិទ្ធិផ្ទាល់ខ្លួន ហើយដែលកិច្ចប្រឹងប្រែងរបស់ពួកគេបំពេញបន្ថែមលើការងាររបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ លើសពីនេះទៀត ម្ចាស់ជំនួយ និងរដ្ឋាភិបាលនៃប្រទេសជាដៃគូ ប្ដេជ្ញាធ្វើការជាមួយអង្គការសង្គមស៊ីវិលដើម្បីផ្ដល់បរិយាកាសអំណោយផលដែលជួយជំរុញការចូលរួមចំណែករបស់ពួកគេឱ្យឈានទៅដល់កំរិតអតិបរមានៅក្នុងដំណើរការអភិវឌ្ឍន៍កម្ពុជា។

---

[១] សម្រាប់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងសេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស ផែនការសកម្មភាពអាក្រា ក្របខ័ណ្ឌគ្រប់គ្រងជំនួយកម្ពុជា គោលការណ៍ណែនាំ ឯកសារគ្រប់គ្រងជំនួយនានា របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃផ្សេងៗ ក៏ដូចជាមូលដ្ឋានទិន្នន័យស្ដីពីជំនួយអភិវឌ្ឍន៍ផ្លូវការ សូមចូលទៅកាន់គេហទំព័ររបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖ www.cdc-crdb.gov.kh. សម្រាប់ឯកសារ ភាពជាដៃគូទីក្រុងប៊ូសានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាព សូមចូលទៅកាន់គេហទំព័រ៖ http://www.aideffectiveness.org/busanhlf4/en/component/content/article/698.html

សម្រាប់ព័ត៌មានលម្អិតស្តីពីប្រសិទ្ធិភាពអភិវឌ្ឍន៍នៃសង្គមស៊ីវិល និងការអំពាវនាវសូមអោយមានបរិយាកាសអំណោយផល (Enabling Environment) សម្រាប់សង្គមស៊ីវិល សូមចូលទៅកាន់គេហទំព័រ www.cso-effectiveness.org ។

# ១ សេចក្តីផ្តើម

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួន[២] រៀបចំកិច្ចប្រជុំយ៉ាងទៀងទាត់ដើម្បីពិភាក្សាលើគម្រោង អាទិភាពក្នុងការអភិវឌ្ឍនៅប្រទេសកម្ពុជា និង ជំនួយអភិវឌ្ឍន៍ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍។ វេទិកាសម្រាប់កិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (*Cambodia Development Cooperation Forum* "CDCF") គឺជាកិច្ចប្រជុំកំពូល ដែលត្រូវប្រារព្ធជាទៀងរាល់១៥ ឬ១៨ខែម្តង។ នៅចន្លោះកិច្ចប្រជុំ CDCF មានកិច្ចប្រជុំ GDCC ដែលជាកិច្ចប្រជុំជាន់ខ្ពស់ ប្រចាំត្រីមាសឬប្រចាំឆមាសដែលរៀបចំឡើងដើម្បីពិភាក្សា និងតាមដានការសន្យាទាំងឡាយដែលកំនត់នៅក្នុងកិច្ច ប្រជុំ CDCF។ ក្រៅពីកិច្ចប្រជុំជាន់ខ្ពស់គេឃើញមានកិច្ចប្រជុំររបស់ក្រុមការងារបច្ចេកទេសទាំងដប់ប្រាំបួន ដែលភាគច្រើនត្រូវបានរៀបចំឡើងតាមវិស័យដែលចូលរួមដោយតំណាងរាជរដ្ឋាភិបាល (តាមក្រសួងនីមួយៗ) និងដៃគូអភិវឌ្ឍន៍ដើម្បីពិភាក្សាអំពីផែនការការផ្តល់ជំនួយ ការសម្របសម្រួលជំនួយ និងបញ្ហាពាក់ព័ន្ធនានា។

ទន្ទឹមនឹងនេះ ក៏មានតំណាងអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមនៅក្នុងកិច្ចប្រជុំ CDCF និង GDCC និងនៅក្នុងក្រុមការងារបច្ចេកទេសចំនួន ១៦ ក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង១៩។ តាមរយៈកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គការមិនមែនរដ្ឋាភិបាលជាមួយសហគមន៍ ប្រជាពលរដ្ឋក្រីក្រ និងជនដែលងាយនឹងរងគ្រោះនៅប្រទេសកម្ពុជាបានធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាលជាច្រើនមានមតិ និងយោបល់ដើម្បីរួមចំណែកដល់ការពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនេះ និងធានាថាសម្លេងឬសេចក្តីត្រូវការរបស់សហគមន៍ដែលពួកគេធ្វើការជាមួយត្រូវបានស្តាប់ឮដោយតំណាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

---

[២] ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ (ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ) ប្រព័ន្ធសហប្រជាជាតិ (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ មូលនិធិកុមារសហប្រជាជាតិ កម្មវិធីស្បៀងអាហារពិភពលោក ។ល។) និង ម្ចាស់ជំនួយឧបតោភាគី (ជប៉ុន សហរដ្ឋអាមេរិក ។ល។) "ដៃគូអភិវឌ្ឍន៍" និង "ម្ចាស់ជំនួយ" ត្រូវបានប្រើជំនួសឱ្យគ្នានៅក្នុងព្រឹត្តិបត្រនេះ។

# ២ ការវិវត្តន៍នៃយន្តការសម្របសម្រួលជំនួយ រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

ដូចមានបង្ហាញជូននៅក្នុងរូបខាងក្រោម ការពិភាក្សា និងការសម្របសម្រួលជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់កម្ពុជា រវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍បានចាប់ផ្តើមដោយការរៀបចំជាសន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីការស្តារនិងកសាងប្រទេស កម្ពុជា (*The Ministerial Conference on the Rehabilitation and Reconstruction of Cambodia* “MCRRC” ) នៅទីក្រុងតូក្យូ ក្នុងឆ្នាំ១៩៩២។ សន្និសីទនេះបានបង្កើតឡើងនូវកិច្ចប្រជុំនៃគណៈកម្មាធិការអន្តរជាតិ ស្តីពីការស្តារប្រទេសកម្ពុជាឡើងវិញ (the International Committee on the Rehabilitation of Cambodia “ICORC” ) ហើយត្រូវបានប្រារព្ធធ្វើជាលើកដំបូងនៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩៣។ កិច្ចប្រជុំ ICORC ត្រូវបានជំនួសដោយកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ (the Consultative Group “CG” ) ក្នុងឆ្នាំ១៩៩៦ និងត្រូវបានបន្តរហូតដល់ឆ្នាំ២០០៦ ហើយត្រូវបានប្តូរទៅជាកិច្ចប្រជុំ CDCF ក្នុងឆ្នាំ២០០៧។ ការវិវត្តន៍ចុងក្រោយនេះ បានបង្កើននូវភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់កម្ពុជាលើកិច្ចប្រជុំរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រី។

ចាប់តាំងពីឆ្នាំ១៩៩២ ដល់ឆ្នាំ២០០១ កិច្ចប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីការស្តារនិងកសាងប្រទេសកម្ពុជា (MCRRC) កិច្ចប្រជុំនៃគណៈកម្មាធិការអន្តរជាតិស្តីពីការស្តារប្រទេសកម្ពុជាឡើងវិញ (ICORC) និងកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ (CG) ត្រូវបានសម្របសម្រួលដោយ និងស្ថិតក្រោមអធិបតីភាពរបស់ម្ចាស់ជំនួយ។ ចាប់ពីឆ្នាំ២០០៧មក រាជរដ្ឋាភិបាលបានដឹកនាំការសម្របសម្រួល និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំនានាជាមួយដៃគូអភិវឌ្ឍន៍។ ក្នុងអំឡុងពេលទាំងនេះ យ៉ាងហោចណាស់មានតំណាងអង្គការមិនមែនរដ្ឋាភិបាលពីររូបដែលបានចូលរួម និងតំណាងសម្លេងរបស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា។ ចាប់ពីឆ្នាំ២០០៧មក ដោយមានការកើនឡើងនូវភាពជាម្ចាស់របស់រដ្ឋាភិបាល វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum ) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC ) និងអង្គការមេឌីខាំ (MEDi- CAM ) បានបំពេញមុខងារតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំនានានៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF)។ តួនាទីចំបងនៃអ្នកតំណាងទាំងនេះ គឺ

លើកឡើងនូវកង្វល់នានាទាក់ទងនឹងការអភិវឌ្ឍន៍របស់កម្ពុជា ដោយប្រើសេចក្តីថ្លែងការណ៍អំពីការតាមដានរបស់អង្គការមិនមែនរដ្ឋាភិបាលលើកំណែទម្រង់ និងវឌ្ឍនភាពសំខាន់ៗនៃបណ្តាអាទិភាពនៃការអភិវឌ្ឍន៍ ។

ជាងនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជាបានពិចារណាលើគំនិតផ្តួចផ្តើមមួយក្នុងការបញ្ចូលយន្តការ CDCF នេះ ជាមួយនឹងវេទិការវាងរដ្ឋាភិបាលនិងផ្នែកឯកជនទៅជា " វេទិកាស្តីពីការអភិវឌ្ឍន៍កម្ពុជា (CDF) " ដែលនឹងដើរតួជាយន្តការមួយ សម្រាប់តួអង្គរាជរដ្ឋាភិបាល និងតួអង្គនានាដែលចូលរួមក្នុងការអភិវឌ្ឍន៍កម្ពុជា រួមមានសហគមន៍ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន សង្គមស៊ីវិល និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាបញ្ហាដែលទាក់ទងដល់ការអភិវឌ្ឍ ផ្នែកសាធារណៈ និងផ្នែកឯកជន រួមទាំងការអភិវឌ្ឍនានា នៅកម្ពុជាទាំងមូល ។ គេមិនដឹងច្បាស់ទេថា នៅពេលណាដែលគំនិតផ្តួចផ្តើមនេះនឹងអាចសម្រេចបាន ។

## កិច្ចដំណើរការវិវត្តនៃយន្តការសម្របសម្រួលជំនួយសម្រាប់កម្ពុជា




កំណត់សម្គាល់ៈ

- * កិច្ចប្រជុំ ICORC លើកទី ១ ត្រូវបានដឹកនាំដោយប្រទេសបារាំង និងសម្របសម្រួលដោយកម្មវិធីអភិវឌ្ឍន៍ សហប្រជាជាតិ (UNDP)
- ** កិច្ចប្រជុំ CG លើកទី ១ ត្រូវបានដឹកនាំកិច្ចប្រជុំរួមដោយធនាគារពិភពលោក និងប្រទេសជប៉ុន
- កិច្ចប្រជុំ CDF : វេទិកាស្តីពីការអភិវឌ្ឍន៍កម្ពុជា

Chairs: សហប្រធាន

Venue: ទីកន្លែង

# ៣ យន្តការបច្ចុប្បន្នសម្រាប់ការពិភាក្សារវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

*វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា*[៣] (CDCF) គឺជាកិច្ចប្រជុំកម្រិតកំពូលរវាងរាជរដ្ឋា–ភិបាលនិង ដៃគូអភិវឌ្ឍន៍ដើម្បី ១) ពិភាក្សាលើវឌ្ឍនភាពរួមនៃកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម (រួមបញ្ចូលនូវការពិនិត្យមើលវឌ្ឍនភាព ដែលសម្រេចបានទៅលើសូចនាករតាមដានរួម (Joint Monitoring Indicators "JMIs") ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំ CDCF លើកមុន) ២) ឯកភាពលើសូចនាករតាមដានរួម (JMIs)[4] សម្រាប់វាស់វែងវឌ្ឍនភាពនៅឆ្នាំបន្ទាប់ និង ៣) ដៃគូអភិវឌ្ឍន៍សន្យាទឹកប្រាក់ជំនួយរបស់ខ្លួនដែលត្រូវផ្ដល់ជូនកម្ពុជាសម្រាប់ឆ្នាំបន្ទាប់។ ជាទូទៅ វេទិកានេះត្រូវបានចូលរួមជាអធិបតីភាពដោយសម្ដេចនាយករដ្ឋមន្ត្រី ដែលដឹកនាំអង្គប្រជុំដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានការចូលរួមពីសំណាក់រដ្ឋមន្ត្រី និងរដ្ឋលេខាធិការតាមក្រសួងនីមួយៗ និង អង្គទូត ក៏ដូចជាប្រធានស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា (ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ)។ ចំពោះភាគីដៃគូអភិវឌ្ឍន៍ ធនាគារពិភពលោកបំពេញតួនាទីជាអ្នកសម្របសម្រួល និងគាំទ្រក្នុងឋានៈជាអ្នកសម្របសម្រួលនាំមុខនៃដៃគូអភិវឌ្ឍន៍។

ការងាររៀបចំសម្រាប់កិច្ចប្រជុំ CDCF និង GDCC ត្រូវបានដឹកនាំដោយ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CRDB/CDC) ដោយសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈក្រុមការងារបច្ចេកទេសស្ដីពីភាពជាដៃគូ និងសុខដុមនីយកម្ម[៥] (TWG-P&H) ដែលអគ្គលេខាធិការ CRDB/CDC គឺជាប្រធាន។ ក្រុមការងារបច្ចេកទេសនេះដើរតួជា "ស្ថាប័នស្នូល" និងជា "សេវា ច្រកចេញ–ចូលតែមួយ" ក្នុងទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងបណ្ដាប្រទេសអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជាម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា។ ក្រុមការងារបច្ចេកទេសនេះ

---

[៣] សម្រាប់ការពន្យល់លម្អិតស្ដីពី CDCF សូមមើលគោលការណ៍ណែនាំនៅក្នុងឯកសារ "វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា: កម្មវត្ថុ និង នីតិវិធី" ដែលអាចទាញយកបានតាមរយៈគេហទំព័ររបស់ CRDB/CDC

[៤] សូមមើលប្រអប់ខាងក្រោមស្ដីពីសូចនាករតាមដានរួម។

[៥] សំរាប់ព័ត៌មានលំអិតអំពីក្រុមការងារបច្ចេកទេស P&H សូមមើលគេហទំព័ររបស់ CRDB/CDC

ក៏ដើរតួនាទីជាភ្នាក់ងារទំនាក់ទំនង និងជា "សេវាច្រកចេញ–ចូលតែមួយ" ក្នុងទំនាក់ទំនងរវាងបណ្តាក្រសួង និងស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលចំពោះការទទួល និង/ឬការបែងចែកជំនួយអភិវឌ្ឍន៍មកកាន់កម្ពុជា។ ក្រុមការងារបច្ចេកទេសនេះក៏ផ្តល់ការគាំទ្របច្ចេកទេស ទៅដល់គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ ដែលជាយន្តការមួយសម្រាប់ពិភាក្សា និងរៀបចំគោលនយោបាយនានា ព្រមទាំងផ្តល់គំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារ និងពង្រឹងយន្តការសម្របសម្រួលរបស់ក្រុមការងារបច្ចេកទេសចំរុះ។ នៅក្នុងក្រុមការងារបច្ចេកទេសភាពជាដៃគូ និងសុខដុមនីយកម្ម (TWG-P&H) មានតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួនបីរួមមាន CCC MEDiCAM និង NGO Forum ។ អង្គការមិនមែនរដ្ឋាភិបាលទាំងបីនេះ ក៏ត្រូវបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំអន្តរក្រុមការងារបច្ចេកទេសចំរុះ និងការកសាងសមត្ថភាពនៅក្នុងឆ្នាំ២០១១ ដោយ CRDB/CDC ដូចជាអភិក្រមគ្រប់គ្រងទូទាំង កម្មវិធី (PBA) ដែលជំរុញការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេស (Country System ) និងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងជំនួយនៅប្រទេសហ្វីលីពីនសម្រាប់មន្ត្រីរដ្ឋាភិបាល[៦] ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំ CDCF មានអ្នកចូលរួមប្រមាណពី ២០០ ទៅ ៣០០ នាក់ និងមានតំណាងជាន់ខ្ពស់មកពីក្រសួង/ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលគាំទ្រដោយបុគ្គលិកបច្ចេកទេស និងមន្ត្រីជាន់ខ្ពស់ ដែលបម្រើការនៅតាមក្រសួង/ស្ថាប័ននានារបស់រដ្ឋាភិបាល និងនៅកម្រិតក្រុមការងារបច្ចេកទេស។ នៅក្នុងកិច្ចប្រជុំនេះ អង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់*អាសនៈមួយកន្លែង ប៉ុន្តែមានតំណាងបីរូប* ដែលតំណាងទាំងនេះត្រូវបានជ្រើសចេញពីសមាជិកភាពរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) មេឌីខាំ (MEDiCAM) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum )។ ជាទូទៅ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំនៅឯការិយាល័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្នុងចន្លោះពេលជាទៀងទាត់ពី ១៥ ទៅ ១៨ ខែម្តង។ កិច្ចប្រជុំ CDCF នៅកម្ពុជា គូសបញ្ជាក់ជាថ្មីម្តងទៀតនូវការសន្យា ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍លេខ១៩នៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលចែងថាបណ្តាប្រទេសដៃគូ និងម្ចាស់ជំនួយនានាប្តេជ្ញារួមគ្នាក្នុងការធ្វើការជាមួយគ្នាដើម្បីបង្កើតក្របខណ្ឌនានាដោយមានកិច្ចព្រមព្រៀងជាមួយគ្នា ដែលក្របខណ្ឌទាំងនោះផ្តល់នូវការវាយតម្លៃនៃការអនុវត្តការងារប្រកបដោយភាពអាចជឿទុកចិត្តបាន តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធនានារបស់ប្រទេស។ ចំពោះព័ត៌មានលំអិតអំពីដំណើរការនៃពិភាក្សានេះ សូមចូលទៅពិនិត្យលើគេហទំព័ររបស់ CRDB/CDC: www.cdc-crdb.gov.kh ។

---

[៦] ដូចបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំស្តីពីមុខងារ និងការប្រព្រឹត្តិទៅនៃក្រុមការងារបច្ចេកទេស (2010) NGOs ត្រូវបានអញ្ជើញជាសមាជិកពេញសិទ្ធិនៅក្នុងក្រុមការងារបច្ចេកទេស និងត្រូវបានអញ្ជើញ និងដាក់បញ្ចូលទៅក្នុងការកសាងសមត្ថភាពដែលមាននៅតាមក្រុមការងារបច្ចេកទេសនានា។

# យន្តការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

**CDCF**

- ពិនិត្យមើលវឌ្ឍនភាពអភិវឌ្ឍន៍ (សូចនាករតាមដានរួម និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ)
- អនុម័តអាទិភាពអភិវឌ្ឍន៍ថ្មី (សូចនាករតាមដានរួមថ្មី)
- ការសន្យាផ្តល់ជំនួយ(ជាទឹកប្រាក់) ដោយម្ចាស់ជំនួយ

**GDCC**

- យន្តការតាមដានការអនុវត្តសូចនាករតាមដានរួម
- ធានាការសម្របសម្រួល និងដំណើរការ និងការប្រព្រឹត្តិទៅនៃ **TWG**

ក្រុមការងារបច្ចេកទេសសុខាភិបាល (១)

ក្រុមការងារបច្ចេកទេសផែនការ និង ការកាត់បន្ថយភាពក្រីក្រ (២)

...

ក្រុមការងារបច្ចេកទេសយេនឌ័រ (១៩)

សូចនាករតាមដានរួម (JMIs) គឺជាសូចនាកររយៈពេលខ្លីនិងផ្អែកលើលទ្ធផល និងតំណាងឱ្យអាទិភាពអភិវឌ្ឍន៍ និងបង្ហាញពីការប្តេជ្ញាអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ (ដែលមានបញ្ជាក់ពីគោលដៅ និងសកម្មភាពសំខាន់ ដែលត្រូវសម្រេចឱ្យបានមុនពេលកិច្ចប្រជុំបន្ទាប់) ដែលរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ប្តេជ្ញា សម្រេចឱ្យបានក្នុងចន្លោះពេលពីកិច្ចប្រជុំ CDCF មួយទៅកិច្ចប្រជុំ CDCF មួយទៀត។ វឌ្ឍនភាពដែលសម្រេចបានទៅលើ JMIs ត្រូវបានតាមដានមើលដោយភាគី ដែលពាក់ព័ន្ធ រួមមាន: រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល។

យោងតាមរូបដែលបង្ហាញខាងលើ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍[7](GDCC) មានតួនាទី ទ្រទ្រង់នូវដំណើរការនៃកិច្ចប្រជុំ CDCF ជាយន្តការតាមដានមួយ។ GDCC គឺជាវេទិកាមួយសម្រាប់ពិភាក្សាគោលនយោបាយ និងចែករំលែកព័ត៌មានអំពីគោលនយោបាយ កម្មវិធី កំណែទម្រង់ និងសកម្មភាពជាក់លាក់នានាស្តីពីបញ្ហាអន្តរវិស័យ។ វេទិកានេះផ្តោតការយកចិត្តទុកដាក់លើការពិនិត្យមើលនូវវឌ្ឍនភាព ដែលសម្រេចបានក្នុងការអនុវត្តសូចនាករ តាមដានរួមគ្នា (JMI) ការពិភាក្សាអំពីបញ្ហាអាទិភាពនានាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់កម្ពុជារួមមានការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងបន្តការពិនិត្យមើលបញ្ហាសេសសល់ដែលមិនមានលក្ខណៈបច្ចេកទេស ដែលមិនទាន់អាចសំរេចបាននៅកំរិត ក្រុមការងារបច្ចេកទេស។ *GDCC មានទំនាក់ទំនងជិតស្និទ្ធជាមួយ CDCF ដោយសារកិច្ចប្រជុំនេះផ្តោតការយកចិត្តទុកដាក់លើការតាមដានការអនុវត្តសូចនាករតាមដានរួមគ្នា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំ CDCF*។ តាមធម្មតា កិច្ចប្រជុំ GDCC ត្រូវបានរៀបចំពីរលើកក្នុងមួយឆ្នាំ (ពោលគឺមិនលើសបីដងក្នុងមួយឆ្នាំ) ដែលតំណាងជាន់ខ្ពស់មកពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ពិភាក្សាលើបញ្ហាដែលបានបញ្ជាក់ខាងលើ។ កិច្ចប្រជុំ GDCC នេះ តែងប្រព្រឹត្តទៅនៅវិមានរដ្ឋាភិបាល ដែលស្ថិតនៅក្នុងការិយាល័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងស្ថិតក្រោមអធិបតីភាពឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំណែកឯធនាគារពិភពលោកគឺជាអ្នកសម្របសម្រួលនាំមុខខាងផ្នែកដៃគូអភិវឌ្ឍន៍។

GDCC គឺជាវេទិកាកម្រិតខ្ពស់ សម្រាប់កិច្ចការសម្របសម្រួល ពិភាក្សា និងចែករំលែកព័ត៌មានអំពីគោលនយោបាយ និង បញ្ហាសំខាន់ៗ ព្រមទាំងសារៈសំខាន់ដ៏ទៃទៀតទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា។ សមាជិកនៃ វេទិកានេះរួមមាន រដ្ឋមន្ត្រី ឬថ្នាក់ដឹកនាំស្ថាប័ននានារបស់រដ្ឋាភិបាល អង្គទូត ឬប្រមុខបេសកកម្មការទូត និងប្រធានស្ថាប័ន ហិរញ្ញវត្ថុអន្តរជាតិ។ GDCC មានបំណងធានាឱ្យមានការសម្របសម្រួលក្នុងចំណោមក្រុមការងារបច្ចេកទេស ផ្តល់ការណែនាំផ្នែកគោលនយោបាយ កំណត់អាទិភាព និងលើកសំណើរ ឬវិធានការផ្សេងៗ ដើម្បីដោះស្រាយបញ្ហាដែលក្រុមការងារបច្ចេកទេសបានលើកឡើងនិង/ឬកំពុងជួបប្រទះ។

អង្គការមិនមែនរដ្ឋាភិបាលចំនួនបីរួមមាន: CCC MEDiCAM និង NGO Forum ជាធម្មតាត្រូវបានអញ្ជើញដោយCRDB/CDC ដើម្បីចូលរួមក្នុងកិច្ចប្រជុំGDCC នេះ។ ពួកគាត់ជាញឹកញាប់ត្រូវបានផ្តល់ឱកាសក្នុងការបញ្ចេញមតិ និងយោបល់ ឬកង្វល់របស់ខ្លួនអំពីបញ្ហាជាក់លាក់នានា ដោយយោងតាមរបាយការណ៍

៧ ព័ត៌មានលម្អិតពាក់ព័ន្ធ GDCC សូមអានរបាយការណ៍ស្តីពី "គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសនៅកម្ពុជាដោយ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (២០០៦)" ដែលអាចទាញយកបានតាមរយៈគេហទំព័ររបស់ CRDB/CDC ។

ត្រួតពិនិត្យតាមដាន និងឯកសារគោលជំហរដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ។

នៅក្នុងវគ្គ ឬរបៀបវារៈនីមួយៗនៃកិច្ចប្រជុំ តំណាងអង្គការមិនមែនរដ្ឋាភិបាលក៏អាចឆ្លៀតឱកាសធ្វើអន្តរាគមន៍ ជាក់លាក់ទាក់ទងនឹងចំណុចផ្សេងៗនៅក្នុងរបៀបវារៈផងដែរ។ ប្រធានសម័យប្រជុំអាចជំទាស់នឹងបទអន្តរាគមន៍ទាំងឡាយណា ដែលមិនទាក់ទងជាសំខាន់ឬជិតស្និទ្ធទៅនឹងរបៀបវារៈ។ ចំនួននៃអ្នកចូលរួមបន្ថែមមកពីអង្គការមិនមែនរដ្ឋាភិបាល គឺអាស្រ័យលើការអនុញ្ញាតពីCRDB/CDC ហើយសំណើសុំការចូលរួមបន្ថែមត្រូវធ្វើតាមរយៈតំណាងអង្គការមិនមែនរដ្ឋាភិបាលទាំងបី។

ក្រុមការងារបច្ចេកទេស[៨] (TWGs) ជាយន្តការសម្របសម្រួលមានលក្ខណៈបច្ចេកទេសនៅកំរិតក្រសួង ឬអន្តរក្រសួង អាស្រ័យតាមទំហំការងារនិងផែនការអភិវឌ្ឍន៍វិស័យដែលត្រូវការសហការរវាងស្ថាប័ន។ ក្រុមការងារបច្ចេកទេសមានសមាសភាពឬសមាជិកមកពីក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ ជាទូទៅ ប្រធានក្រុមការងារបច្ចេកទេសជាមន្ត្រីជាន់ខ្ពស់របស់ក្រសួងឬស្ថាប័នរបស់រាជរដ្ឋាភិបាល។ ក្រុមការងារបច្ចេកទេសមានមុខងារសម្របសម្រួលជំនួយនៅកំរិតក្រសួងឬវិស័យ(អន្តរក្រសួង) តែមិនមែនជាយន្តការសម្រេចចិត្តជំនួសតួនាទីក្រសួង ឬស្ថាប័នដែលមានស្រាប់នោះទេ ការសម្រេចចិត្តនៅក្នុងក្រុមការងារបច្ចេកទេសគឺប្រធានក្រុមការងារបច្ចេកទេស ដោយមានការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ និង/ឬអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលជាអ្នកផ្តល់ជំនួយ ព្រមទាំងមានការពិគ្រោះយោបល់ជាមួយសមាជិកផ្សេងៗ ដែលក្នុងនោះមានតំណាងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសទាំងនេះរួមមាន៖ ១)ក្រសួងស្ថាប័នសាមីរៀបចំផែនការសកម្មភាព និងយុទ្ធសាស្ត្រសម្រាប់វិស័យ និងសូចនាករតាមដានរួម និងអាចមានការពិគ្រោះយោបល់ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងសមាជិក ២) គៀងគរ និងសម្របសម្រួលការគាំទ្រជំនួយ(ហិរញ្ញវត្ថុ និងបច្ចេកទេស)ពីសំណាក់ដៃគូអភិវឌ្ឍន៍ចំពោះការអនុវត្តន៍ផែនការ និងយុទ្ធសាស្ត្រលើវិស័យទាំងនោះ និង ៣) បង្កើត និងត្រួតពិនិត្យសូចនាករតាមដានរួមសម្រាប់ក្រុមការងារបច្ចេកទេស។ នៅក្នុងចំណោមក្រុមការងារបច្ចេកទេសសរុបទាំង ១៩ មានតំណាងនៃអង្គការមិនមែនរដ្ឋាភិបាលមួយ ឬច្រើនជាងមួយចូលរួមជាសមាជិកនៅក្នុងក្រុមការងារបច្ចេកទេសចំនួន១៦។ ក្រុមការងារបច្ចេកទេសដំណើរការតាមគោលការណ៍ណែនាំ (ថ្មី)ស្តីពីមុខងារ និងការប្រព្រឹត្តិទៅនៃក្រុមការងារបច្ចេកទេស ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំ GDCC លើកទី១៨ កាលពីខែតុលា ឆ្នាំ២០១០។ គោលការណ៍ណែនាំនោះបានផ្តល់នូវការគាំទ្រផ្នែកប្រឹក្សាចំពោះក្រុមការងារបច្ចេកទេសអំពីការរៀបចំ និងវិសាលភាពនៃការងារ។ ក្រុម

[៨] តារាងបញ្ជីរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅក្នុងក្រុមការងារបច្ចេកទេសត្រូវបានធ្វើបច្ចុប្បន្នកម្ម និងអាចទាញយកបានពីគេហទំព័រ CRDB/CDC: www.cdc-crdb.gov.kh

ការងារបច្ចេកទេសអាចត្រូវបង្កើន ឬបន្ថយអាស្រ័យលើភាពចាំបាច់ និងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល និងមានការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ ។ ក្រុមការងារបច្ចេកទេសនានា ដែលមាន សមាសភាព ឬមានតំណាង[៩] របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចប្រជុំនានារបស់ខ្លួន ត្រូវបានគូសបញ្ជាក់ និងសរសេរជាអក្សរដិតខ្មៅ និងទ្រេតនៅក្នុងប្រអប់ខាងក្រោមនេះ :

### បញ្ជីរឈ្មោះក្រុមការងារបច្ចេកទេសទាំង ១៩គិតត្រឹមខែធ្នូ ឆ្នាំ២០១១

| | |
|---|---|
| ***១. កសិកម្មនិងធនធានទឹក*** | ***១១. ដីធ្លី*** |
| ***២. វិមជ្ឈការ និង វិសហមជ្ឈការ*** | ***១២. កំណែទម្រង់ច្បាប់និងតុលាការ*** |
| ***៣. អប់រំ*** | ***១៣. សកម្មភាពមីន*** |
| ***៤. ជលផល*** | ***១៤. ភាពជាដៃគូ និងសុខដុមនីយកម្ម*** |
| ***៥. សន្តិសុខស្បៀង និង អាហារូបត្ថម្ភ*** | ***១៥. ផែនការ និងការកាត់បន្ថយភាពក្រីក្រ*** |
| ***៦. ព្រៃឈើ និង បរិស្ថាន*** | *១៦. ការអភិវឌ្ឍន៍វិស័យឯកជន* |
| ***៧. យេនឌ័រ*** | ១៧. កំណែទម្រង់រដ្ឋបាលសាធារណៈ |
| ***៨. សុខាភិបាល*** | ***១៨. គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*** |
| ***៩. មេរោគអេដស៍ជម្ងឺអេដស៍*** | ***១៩. ផ្គត់ផ្គង់ទឹកជនបទ អនាម័យ និងការរស់នៅស្អាត*** |
| *១០.* ហេដ្ឋារចនាសម្ព័ន្ធ និង សមាហរណកម្មតំបន់ | |

* ឈ្មោះក្រុមការងារបច្ចេកទេសសរសេរជាអក្សរដិតនិងទ្រេតបង្ហាញថា អង្គការមិនមែនរដ្ឋាភិបាលបានចូលរួមនៅក្នុងក្រុមបច្ចេកទេសទាំងនេះ ។ ចំពោះព័ត៌មានសម្រាប់ទាក់ទងអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងក្រុមបច្ចេកទេសទាំងនេះសូមមើលឧបសម្ព័ន្ធ ។

[៩] តារាងបញ្ជីអ្នកតំណាង NGO នៅក្នុងក្រុមការងារបច្ចេកទេសនានា អាចរកបាននៅ NGO Forum និងអាចទាញយកពីគេហទំព័រ NGO Forum តាមអាសយដ្ឋាន www.ngoforum.org.kh

# ៤ ហេតុអ្វីបានជាអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល[១០] គប្បីចូលរួមក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF ?

មានមូលហេតុចំបងចំនួនបួនចំពោះការដែលសង្គមស៊ីវិល, អង្គការមិនមែនរដ្ឋាភិបាល (CSOs/NGOs ) គប្បីចូលរួមក្នុងកិច្ចប្រជុំ CDCF, GDCC និង TWGs :

១ ) ក្នុងដំណើរការ និងកិច្ចប្រជុំនានានៃCDCF, GDCC និង TWGs, CSOs/NGOs អាចទទួលបានអត្ថប្រយោជន៍ពីព័ត៌មានជាច្រើនដែលចែករំលែកដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍អំពីស្ថានភាពនៃការបង្កើត និងការអនុវត្តគោលនយោបាយព្រមទាំងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ដែលគោលនយោបាយ និងកម្មវិធីកំណែទម្រង់ខ្លះពុំទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយ ។ សមត្ថភាព និងជំនាញតស៊ូមតិរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏អាចត្រូវបានលើកកំពស់តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃកិច្ចប្រជុំទាំងនេះ ។

លើសពីនេះទៅទៀត ចំពោះភាគី CSOs/NGOs វិញ តំណាងអង្គការមិនមែនរដ្ឋាភិបាល ពេលខ្លះត្រូវបានផ្តល់ឱកាស ឬអាចចាប់យកឱកាសដើម្បីជូនជាព័ត៌មានដល់អ្នករៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍អំពីផលប៉ះពាល់នៃការអភិវឌ្ឍ ដែលកើតមានឡើងនៅកម្រិតមូលដ្ឋានមកលើប្រជាពលរដ្ឋ ជាពិសេសមកលើប្រជាពលរដ្ឋក្រីក្រ និងងាយទទួលរងគ្រោះដោយយោងលើការតាមដាន ការស្រាវជ្រាវ និងការសង្កេតរបស់ CSOs/NGOs ។ តាមរយៈការចែករំលែកយ៉ាងសកម្មនូវព័ត៌មាននេះ ដល់អ្នករៀបចំ និងអ្នកធ្វើសេចក្តីសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍

[១០] ដោយហេតុថាមានតែ NGOsទេ ដែលចូលរួមក្នុងកិច្ចប្រជុំ TWGs ដូច្នេះពាក្យ“NGO” គឺសំដៅដល់ NGOsទាំងនោះ ។ យ៉ាងណាមិញ គោលបំណងដើមនៃសៀវភៅណែនាំនេះគឺមិនមែនជួយសម្រួលដល់ NGOsប៉ុណ្ណោះទេ ថែមទាំងជួយដល់ក្រុមដ៏ទៃទៀតដែលជាសមាសសធាតុនៃអង្គការសង្គមស៊ីវិល (CSO ) រួមមានក្រុមនិកាយសាសនា សមាគមន៍ សហជីពកម្មករ អង្គការផ្អែកលើសហគមន៍ និងសមាសធាតុដ៏ទៃទៀត ។

អង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមចំណែកជួយតំរង់ទិសកិច្ចពិភាក្សាគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍នានាឱ្យកាន់តែមានលក្ខណៈឆ្លើយតបបន្ថែមទៀតចំពោះតម្រូវការរបស់ពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្រីក្រនិងដែលងាយរងគ្រោះ។

២) CSOs/NGOs អាចយកការចូលរួមនេះទៅប្រើក្នុងយន្តការទាំងបីដើម្បីសូមអោយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយមានគណនេយ្យភាពចំពោះការសន្យា និងការអនុវត្តគោលនយោបាយដែលនឹងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋ និងសង្គមកម្ពុជាទាំងមូល។ យន្តការពិនិត្យតាមដាន និងយន្តការគណនេយ្យភាពទាំងនេះ អាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាល និងម្ចាស់ជំនួយមានគណនេយ្យភាពចំពោះគ្នាទៅវិញទៅមកចំពោះការសន្យារបស់ខ្លួន។ រាជរដ្ឋាភិបាលអាចមានការប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបាននូវកំណែទម្រង់សំខាន់ៗ និងសម្រេចឱ្យបាននូវចំណុចដៅនៃផែនការតាមវិស័យ តាមពេលវេលាគ្រោងជាក់លាក់ ចំណែកឯម្ចាស់ជំនួយអាចមានការប្តេជ្ញាចិត្តក្នុងការលើកកំពស់សុខដុមនីយកម្មជំនួយក្នុងចំណោមម្ចាស់ជំនួយនានា ដើម្បីឱ្យជំនួយអភិវឌ្ឍន៍ស្របជាមួយអាទិភាពនានានៃផែនការអភិវឌ្ឍន៍របស់កម្ពុជា និងដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេស (ពោលគឺប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធលទ្ធកម្មសាធារណៈកម្ពុជា) ក្នុងការផ្តល់ជំនួយមកកាន់កម្ពុជា។

៣) CSOs/NGOs អាចប្រើប្រាស់ឱកាសដែលមាននៅក្នុង TWGs និង GDCC ដើម្បីធ្វើឱ្យមានឥទ្ធិពលចំពោះការបង្កើត និងការអនុវត្ត JMI ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP)[១១] ប្រាំឆ្នាំរបស់កម្ពុជាដែលរៀបចំដោយរាជរដ្ឋាភិបាល ដើម្បីធានាថាសូចនាករតាមដានរួម និងផែនការជាតិទាំងនេះកាន់តែមានលក្ខណៈឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រ និងជនដែលងាយទទួលរងគ្រោះ។ ជាធម្មតា JMIs ត្រូវបានពិភាក្សា និងរៀបចំនៅកម្រិត TWG រួចបញ្ជូនទៅសុំការអនុម័តនៅក្នុងកិច្ចប្រជុំ GDCC និង CDCF ចំណែកឯ NSDP

[១១] NSDP គឺជាគោលនយោបាយអភិវឌ្ឍន៍ជាតិរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលតម្រូវទៅតាមយុទ្ធសាស្ត្រចតុកោណ និងព្យាយាមសំរេចឱ្យបាននូវគោលដៅអាទិភាព ចំណុចដៅ និងសកម្មភាពនានា។ ជាធម្មតា ផែនការអភិវឌ្ឍន៍ជាតិដែលល្អត្រូវមានអាទិភាពផ្នែកគោលនយោបាយយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធកម្មវិធី កម្មវិធីកំណែទម្រង់និងសកម្មភាព ការកំណត់ពេលវេលា ភ្នាក់ងារដឹកនាំ ឬភ្នាក់ងារទទួលខុសត្រូវនិងទិន្នន័យគោលចំណុចដៅ និងតម្រូវការមូលនិធិ (ឬតារាង ធាតុចូល–លទ្ធផល)។ យុទ្ធសាស្ត្រចតុកោណគឺជាវេទិការ ឬរបៀបវារៈ គោលនយោបាយរបស់រដ្ឋាភិបាលនៃគណៈបក្សកាន់អំណាចហើយការណ៍នេះក៏ត្រូវដកស្រង់ ឬប្រើប្រាស់ក្នុងគោលដៅតស៊ូមតិផងដែរ។ ដោយសារ NSDP ត្រូវបានអនុម័តដោយរដ្ឋសភា ដូច្នេះកាន់តែមានលក្ខណៈសមស្របសំរាប់ NGOs ក្នុងការប្រើប្រាស់ឱ្យអស់លទ្ធភាព ឬយោងដល់ NSDP ក្នុងគោលបំណងតស៊ូមតិ។ ទោះបីជាយ៉ាងនេះក្តី គោលនយោបាយជាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណក៏ត្រូវបានដាក់បញ្ចូលនៅក្នុង NSDP ផងដែរ។

វិញ ត្រូវបានដឹកនាំសម្របសម្រួល និងរៀបចំចងក្រងដោយក្រសួងផែនការ ដោយមានការចូលរួមពីសាមីក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងCSOs/NGOs ។ យោងតាមបទពិសោធន៍ និងតាមសំណើនៃគោលការណ៍ណែនាំផ្លូវការរបស់រាជរដ្ឋាភិបាលអំពីការរៀបចំ NSDP សាមីក្រសួង និងស្ថាប័នពាក់ព័ន្ធ រៀបចំសេចក្តីថ្លែងគោលនយោបាយសំខាន់ៗនៃផែនការតាមវិស័យរបស់ខ្លួន រួចបញ្ជូនទៅកាន់ក្រសួងផែនការដើម្បីចងក្រងទៅជា NSDP ។ បន្ទាប់មក គណៈរដ្ឋមន្ត្រីផ្តល់ការអនុម័តលើ NSDP រួចទើបបញ្ជូនសុំការអនុម័តពីរដ្ឋសភា ព្រឹទ្ធសភា និងឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ ។ ហេតុដូចនេះហើយ CSOs/NGOs អាចប្រើប្រាស់របាយការណ៍តាមដានរបស់ខ្លួនអំពីវឌ្ឍនភាពនៃ JMIs និង NSDP ដែលអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ដើម្បីមានឥទ្ធិពលលើការរៀបចំ និងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសមាជិកសភា។ វិធីមួយនេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងរដ្ឋសភា មានគណនេយ្យភាពចំពោះលទ្ធផលនៃការអភិវឌ្ឍន៍ និងចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

៤) ការចូលរួមក្នុងកិច្ចប្រជុំរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានផ្តល់ឱកាសដល់អង្គការសង្គមស៊ីវិល, អង្គការមិនមែនរដ្ឋាភិបាល (CSOs/NGOs) ក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ ទាំងនៅតាមវិស័យ និងនៅក្នុង NSDP ហើយដែលសំខាន់បំផុតគឺផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ពិសេសគឺផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋក្រីក្រ និងដែលងាយទទួលរងគ្រោះ។ ការចូលរួមរបស់ CSOs/NGOs នៅក្នុងយន្តការសម្របសម្រួលជំនួយ ត្រូវបានធានាដោយសេចក្តីថ្លែងការណ៍អន្តរជាតិបីជាបន្តបន្ទាប់ដែលប្រទេសផ្តល់ជំនួយ និងប្រទេសដៃគូ ឬប្រទេសទទួលជំនួយបានអនុម័ត (សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនាឆ្នាំ២០០៥ និងផែនការសកម្មភាពក្រុងអាក្រា នៅឆ្នាំ២០០៨ និងភាពជាដៃគូទីក្រុងប៊ូសាន ដើម្បីសហប្រតិបត្តិការណ៍អភិវឌ្ឍន៍ដែលមានប្រសិទ្ធិផល ខែធ្នូ ឆ្នាំ២០១១)។ នៅក្នុងសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសត្រង់ផ្នែកគោលការណ៍អំពីភាពជាម្ចាស់របស់ប្រទេសមានឃ្លាតែមួយប៉ុណ្ណោះដែល និយាយអំពីការសន្យារបស់ប្រទេសដៃគូ ចំពោះការលើកកំពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងកិច្ចការសម្របសម្រួលជំនួយនៅគ្រប់កម្រិត។ សារៈសំខាន់នៃការចូលរួមរបស់អង្គការសង្គមស៊ីវិល ត្រូវបានបញ្ជាក់បន្ថែមនៅក្នុងសេចក្តីថ្លែងការណ៍អន្តរជាតិគឺផែនការសកម្មភាពក្រុងអាក្រា (២០០៨) និងភាពជាដៃគូទីក្រុងប៊ូសានដើម្បីសហប្រតិបត្តិការណ៍អភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិផល (២០១១)។

នៅឆ្នាំ២០០៨ រដ្ឋមន្ត្រីនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសផ្តល់ជំនួយទទួលបន្ទុកខាងការជំរុញកិច្ចអភិវឌ្ឍន៍ ព្រមទាំងប្រធានស្ថាប័នអភិវឌ្ឍន៍ពហុភាគីនិងទ្វេភាគី បានព្រមព្រៀងលើសេចក្តីថ្លែងការណ៍នៅទីក្រុងAccra (ហៅថា ផែនការសកម្មភាពក្រុងអាក្រា (២០០៨) ឬ AAA) ក្នុងប្រទេសហ្កាណាដើម្បីបង្កើនការអនុវត្តលើសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយ (ថ្ងៃទី២ ខែមិនាឆ្នាំ២០០៥)។ នៅក្នុង AAA ការផ្តោតការយកចិត្តទុកដាក់ជាបន្ថែម ត្រូវបានធ្វើឡើងចំពោះការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការសម្របសម្រួលជំនួយ និងធានាឱ្យបាននូវប្រសិទ្ធភាពជំនួយ និងប្រសិទ្ធភាពនៃការអភិវឌ្ឍន៍នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការពង្រឹងភាពជាម្ចាស់ចំពោះការអភិវឌ្ឍន៍ និងការកសាងភាពជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាព និងពេញលេញសម្រាប់កិច្ចអភិវឌ្ឍន៍។ នៅក្នុងសេចក្តីប្រកាសស្តីពីការពង្រឹងភាពជាម្ចាស់របស់ប្រទេសចំពោះកិច្ចអភិវឌ្ឍន៍ មានចែងថារដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍នឹងបង្កលក្ខណៈឱ្យ CSOs ចូលរួមក្នុងការរៀបចំការអនុវត្ត និងការតាមដានគោលនយោបាយនិងផែនការអភិវឌ្ឍន៍ជាតិ ចំណែកឯម្ចាស់ជំនួយនឹងគាំទ្រចំពោះ កិច្ចប្រឹងប្រែងក្នុងការបង្កើនសមត្ថភាពរបស់តួអង្គអភិវឌ្ឍន៍រាប់ទាំង CSOs ផងដែរ។

នៅក្នុងសេចក្តីថ្លែងការណ៍លេខ២០ នៅត្រង់ផ្នែកស្តីពីការកសាងភាពជាដៃគូឱ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែមានភាពពេញលេញចំពោះការអភិវឌ្ឍន៍នៃ AAA អ្នកផ្តល់ការអនុម័ត (រួមមានម្ចាស់ជំនួយ និងដៃគូ ឬបណ្តាប្រទេសទទួលជំនួយ) យល់ព្រមបង្កើនការចូលរួមរបស់ខ្លួនជាមួយ CSOs ដែលជាតួអង្គអភិវឌ្ឍន៍ឯករាជ្យមួយដែលមានសិទ្ធិផ្ទាល់ខ្លួន ក្នុងការធ្វើឱ្យកិច្ចប្រឹងប្រែងរបស់ពួកគេបំពេញបន្ថែមនូវការងាររបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ ជាមួយនឹងកិច្ចការនេះ ទាំងម្ចាស់ជំនួយនិងប្រទេសដៃគូក៏បានប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រាកដថា ការរួមចំណែករបស់ CSOs ចំពោះការអភិវឌ្ឍន៍ឈានទៅដល់សក្តានុពលពេញលេញរបស់ខ្លួន។ សេចក្តីថ្លែងការណ៍នេះក៏លើកទឹកចិត្តឱ្យ CSOs អនុវត្តគោលការណ៍ទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃជំនួយ និងជំរុញប្រសិទ្ធភាពនៃការអភិវឌ្ឍន៍របស់ CSOs តាមរយៈការកែលំអការសម្របសម្រួលរបស់ CSOs ជាមួយកម្មវិធីនានារបស់រដ្ឋាភិបាល ការលើកកំពស់គណនេយ្យភាពរបស់ CSOs ចំពោះលទ្ធផល និងការកែលំអព័ត៌មានស្តីពីសកម្មភាពរបស់ CSOs។ ជាចុងក្រោយ ម្ចាស់ជំនួយ និងរដ្ឋាភិបាលដៃគូប្តេជ្ញាធ្វើការជាមួយ CSOs ក្នុងការផ្តល់បរិយាកាសអំណោយផលដែលលើកកំពស់ជាអតិបរមានូវការរួមចំណែករបស់ CSOs ចំពោះការអភិវឌ្ឍ។ ដោយយោងលើសេចក្តីថ្លែងការណ៍ទាំងបីនេះ CSOs/NGOs នៅកម្ពុជាមានប្រកចូលច្បាស់លាស់តាមការប្តេជ្ញាជាអន្តរជាតិក្នុងការចូលរួមក្នុងយន្តការសម្របសម្រួលជំនួយ ដើម្បីកសាងភាពជាម្ចាស់របស់ប្រទេសអំពីគំរូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។

សេចក្តីថ្លែងការណ៍ចុងក្រោយនៅទីក្រុងប៊ូសានសាធារណៈរដ្ឋកូរ៉េ (ខាងត្បូង) ស្តីពីភាពជាដៃគូទីក្រុងប៊ូសាន ដើម្បីសហប្រតិបត្តិការណ៍អភិវឌ្ឍន៍ដែលមានប្រសិទ្ធិផល (២០១១) បានបញ្ជាក់ការធានាបន្ថែមទៀតថានឹងផ្តល់បរិយាកាសអំណោយផលដល់ការបំពេញតួនាទីជាតួអង្គអភិវឌ្ឍន៍ឯករាជ្យ និងធានា

នូវការចូលរួមជាអតិបរមារបស់សង្គមស៊ីវិលទៅក្នុងការអភិវឌ្ឍន៍។ ក្នុងនោះក៏មានការបញ្ជាក់ពីការទទួលខុសត្រូវរបស់សង្គមស៊ីវិលខ្លួនឯងផងដែរថា លើកទឹកចិត្តសង្គមស៊ីវិលអោយពង្រឹងគណនេយ្យភាពរបស់ខ្លួន និងការចូលរួមចំណែកសម្រេចបាននូវប្រសិទ្ធផលនៃការអភិវឌ្ឍន៍ យោងតាមគោលការណ៍អ៊ីស្តាន់ប៊ុល និងក្របខណ្ឌអន្តរជាតិសម្រាប់ប្រសិទ្ធិផលនៃការអភិវឌ្ឍន៍របស់អង្គការសង្គមស៊ីវិល។ គេអាចទាញយកបានឯកសារនេះពីវែបសាយ : www.busanhlf4.org និងសេចក្តីថ្លែងការណ៍ក្រុងប៉ារីសនិង AAA ពីវែបសាយរបស់ CRDB/CDC: www.cdc-crdb.gov.kh.

# ៥ តើអង្គការមិនមែនរដ្ឋាភិបាលចូលរួមយ៉ាងដូចម្តេច ឲ្យមានប្រសិទ្ធភាពនៅក្នុងកិច្ចប្រជុំ GDCC និង CDCF?

គេឃើញមានវិធីសាស្ត្រចំនួនបី ដែលអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលអាចចូលរួមយ៉ាងសកម្ម ក្នុងកិច្ចប្រជុំ GDCC និង CDCF ។

១) ចំពោះកិច្ចប្រជុំក្រុមការងារបច្ចេកទេស[១២] CSOs/NGOs គប្បីសម្របសម្រួលឱ្យបានល្អប្រសើរ ក្នុងចំណោមសមាជិក ឬវិស័យរបស់ខ្លួនមុនពេលយកទៅពិភាក្សាក្នុងកិច្ចប្រជុំ ជាពិសេស តាមរយៈការមានជាអ្នកសម្របសម្រួលនាំមុខនៃ NGOs ។ ជាអនុសាសន៍ អង្គការមិនមែនរដ្ឋាភិបាលនាំមុខនានា ឬតំណាងនៃអង្គការមិនមែនរដ្ឋាភិបាល[១៣]គប្បីរៀបចំកិច្ចប្រជុំជាមុនក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងក្រុមឬវិស័យដូចគ្នា រួចធ្វើការពិភាក្សាលើបញ្ហាអាទិភាព រួមទាំងបញ្ហាប្រឈមទាក់ទងនឹងការរៀបចំ និងការអនុវត្តគោលនយោបាយ ដែលត្រូវលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស ។ កិច្ចពិភាក្សានានាត្រូវរៀបចំដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ ឬដោយមានការគាំទ្រពីការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ ដែលអាចជូនជាព័ត៌មានប្រកបដោយភាពអាចជឿទុកចិត្តបាន ទៅដល់អ្នករៀបចំគោលនយោបាយនិងអ្នកសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍ដើម្បីពិចារណា និងដើម្បីចាត់វិធានការនានា។ តំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើការទំនាក់ទំនងជាប្រចាំ ឬ

[១២] សូមអានព័ត៌មានលំអិតនៅក្នុងគោលការណ៍ណែនាំអំពីមុខងារ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេស ដែលបានអនុម័តនៅខែ តុលា ឆ្នាំ ២០១០ ដែលគេអាចទាញយកពីគេហទំព័ររបស់ CRDB/CDC តាមអាស័យដ្ឋាន www.cdc-crdb.gov.kh ។ ជាការសំខាន់មួយសំរាប់NGOsក្នុងការអាន "សេចក្តីសង្ខេបនៃរបាយការណ៍ស្តីពីការវាយតម្លៃអំពីការចូលរួម និងភាពជាតំណាងរបស់ NGO នៅក្នុង TWGs ដែលបោះផ្សាយដោយគម្រោងស្តីពីប្រសិទ្ធភាពជំនួយនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នៅឆ្នាំ ២០១១ ដែលគេអាចទាញយកតាមវេបសាយ http://www.ngoforum.org.kh/eng/core/enpublications.php?docs=aepdoc

[១៣] តំណាង NGO សំដៅដល់ NGOsមួយឬច្រើន ដែលរដ្ឋាភិបាលបានទទួលស្គាល់ ឬបានអញ្ជើញឱ្យធ្វើជាសមាជិកមួយរូប (ច្រើនរូប) នៃ TWG ហើយតំណាងនៃ NGO តាមវិស័យឬក្រុមនីមួយៗទាំងនោះ គប្បីធ្វើការដើម្បីជាផលប្រយោជន៍នៃសមាជិក និងប្រជាជនពុំមែនដើម្បីផលប្រយោជន៍របស់អង្គការខ្លួន ឬដើម្បីផលប្រយោជន៍បុគ្គលឡើយ ។

ទំនាក់ទំនងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន ឬអនុក្រុមនៃក្រុមការងារបច្ចេកទេស ដើម្បីធ្វើឱ្យប្រាកដថាព័ត៌មានដែលបានទទួលទាំងឡាយពិតជាព័ត៌មានថ្មីបំផុត ហើយធានាឱ្យបាននូវទំនាក់ទំនងល្អជាមួយសមាជិកអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងក្រុមការងារ ឬវិស័យរបស់ពួកគេ និងរក្សាទំនាក់ទំនងល្អពីសមាជិកនានាទៅកាន់ TWG ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់គប្បីចងចាំថាពួកគេកំពុងដើរតួនាទីជាតំណាងឱ្យទស្សនៈរបស់សមាជិកអង្គការ មិនមែនរដ្ឋាភិបាលនានា ឬក៏ពាំនាំកង្វល់របស់ប្រជាពលរដ្ឋ និងដែលមិនមែនជាប្រយោជន៍ផ្ទាល់ខ្លួន ឬអង្គការតែមួយសម្រាប់ដាក់ជូនជាព័ត៌មាន និងពិភាក្សាក្នុងកិច្ចប្រជុំ TWG ។ តំណាងអង្គការមិនមែនរដ្ឋាភិបាល ត្រូវមានគណនេយ្យភាពចំពោះសមាជិក NGOs របស់ខ្លួន និងចំពោះប្រជាជន ឬអ្នកទទួលផល ។ ជាទូទៅ គណនេយ្យភាពនេះធ្វើឡើងក្នុងទម្រង់សម្របសម្រួល និង/ឬជាតំណាងទៅលើបញ្ហា ដែលបានលើកឡើងដោយអង្គការមិនមែនរដ្ឋាភិបាលជាសមាជិក ហើយធ្វើការរាយការណ៍ឱ្យសមាជិកបានដឹងអំពីលទ្ធផលនៃការពិភាក្សា និងសម្របសម្រួលសកម្មភាពបន្តជាមួយសមាជិក ។

វិធីមួយនៃវិធីដែលមានប្រសិទ្ធភាពបំផុតដើម្បីឱ្យ NGOs ចូលរួមសកម្មនៅក្នុង GDCC និង CDCF គឺតាមរយៈ ការរៀបចំប្រជុំ និងពិភាក្សាជាមុន ។ អង្គការមិនមែនរដ្ឋាភិបាលគប្បីត្រៀមលក្ខណៈឱ្យបានល្អប្រសើរ ហើយសម្រេចចិត្តឱ្យហើយលើអ្វីដែលជាបញ្ហាសំខាន់ ឬបញ្ហាអាទិភាពដែលពួកគេត្រូវលើកឡើងនៅក្នុងកិច្ចប្រជុំនានា ហើយពួកគេក៏ត្រូវធ្វើយ៉ាងណាឱ្យកិច្ចប្រជុំទាំងនោះមានការសម្របសម្រួល ឬការគាំទ្រដោយមានភស្តុតាង ឬការស្រាវជ្រាវប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ឬដោយការសង្កេត ។ អង្គការមិនមែនរដ្ឋាភិបាលគប្បីមានមានការចូលរួមដោយលក្ខណៈស្ថាបនាចំពោះបញ្ហាដែលត្រូវលើកឡើង ដើម្បីកុំឱ្យបញ្ហាទាំងនោះប៉ះពាល់ជាអវិជ្ជមានដល់ទំនាក់ទំនងការងារ ឬការចូលរួមរបស់ពួកគេជាមួយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅគ្រប់កម្រិតដែលអាចប៉ះពាល់ដល់ទំនាក់ទំនងជាមួយសមាជិកនានា នៅក្នុងកំរិត TWG ។ បញ្ហាគន្លឹះទាំងនោះក៏ត្រូវពាក់ព័ន្ធជាមួយចំណុចនានា នៅក្នុងរបៀបវារៈរបស់ GDCC និងCDCFផងដែរ ព្រោះថាតាមរយៈបទពិសោធន៍របស់តំណាងអង្គការមិនមែនរដ្ឋា–ភិបាលក្នុងពេលកន្លងទៅ បញ្ហាដែលមិនពាក់ព័ន្ធច្រើនដល់ចំណុចនានានៅក្នុងរបៀបវារៈ ឬប្រធានបទនៃវគ្គពិភាក្សាអាចត្រូវបានប្រធានអង្គប្រជុំជំទាស់ក្នុងការលើកឡើងជាមតិយោ–បល់ ឬបទអន្តរាគមន៍ ។ ដើម្បីដោះស្រាយបញ្ហានេះ តំណាងអង្គការមិនមែនរដ្ឋាភិបាល (CCC, MEDiCAM និង NGO Forum ) នៅក្នុងក្រុមការងារបច្ចេកទេសស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម ត្រូវមានមូលដ្ឋានសំណើពី NGOs តាមវិស័យដែលធ្វើការជាមួយក្រុម

ការងារបច្ចេកទេសដទៃទៀត ហើយអាចរៀបចំកិច្ចប្រជុំក្នុងចំណោម NGOs នាំមុខតាមវិស័យនានាដើម្បីធ្វើការពិភាក្សា និងកំណត់បញ្ហាអាទិភាពនានា ដែលត្រូវលើកឡើងនៅក្នុង TWG-P&H ដើម្បីសុំការពិចារណា និងដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃ GDCC និង CDCF ។ ក្នុងករណីដែលសំណើនោះមិនត្រូវបានអនុញ្ញាតតំណាងនានានៃអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើអន្តរាគមន៍នៅក្នុងវគ្គឬរបៀបវារៈពាក់ព័ន្ធនៃកិច្ចប្រជុំទាំងពីរនេះតាមរយៈការសម្របសម្រួល និងការពិគ្រោះយោបល់។ ប្រសិនបើកិច្ចប្រឹងប្រែងទាំងនេះមិនបានសម្រេចទេ នោះអង្គការមិនមែនរដ្ឋាភិបាលអាចពិភាក្សា និងកំណត់រកវិធីសាស្រ្តដទៃទៀតដើម្បីធ្វើឱ្យមានឥទ្ធិពលចំពោះការពិភាក្សា ដូចជាយុទ្ធសាស្រ្តតាមប្រព័ន្ធផ្សព្វផ្សាយជាដើម។

២) ចំពោះកិច្ចប្រជុំ GDCC វិញ CSOs/NGOs រៀបចំរបាយការណ៍ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខអក្សរដែលមានចំណងជើងថា "សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការត្រួតពិនិត្យតាមដានសូចនាកររបស់CDCF (ដែលគេស្គាល់ថាជាJMI ) ដាក់ជូនកិច្ចប្រជុំ GDCC" ដែលសង្ខេបនូវវឌ្ឍនភាពតាមការសង្កេតជាដំណាក់កាលអំពីការអនុវត្ត JMIs ។ មានពេលខ្លះឧបសម្ព័ន្ធនានាត្រូវបានភ្ជាប់ជាមួយសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់កិច្ចប្រជុំ GDCC លើបញ្ហាអភិវឌ្ឍន៍សំខាន់ៗ ដែលមិនបានគ្របដណ្តប់ដោយJMIs ។ ក្រោយពេលប្រមូលសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យបញ្ចូលទៅក្នុង "សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យតាមដាន JMIs របស់ CDCF ដាក់ជូនកិច្ចប្រជុំ GDCC " អង្គការមិនមែនរដ្ឋាភិបាលបញ្ជូនរបាយការណ៍នៃសេចក្តីថ្លែងការណ៍/របាយការណ៍ត្រួតពិនិត្យតាមដានដាក់ជូនទាំងតំណាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យត្រូវរៀបរៀងដោយ NGOs តាមវិស័យតាមរយៈ ការពិគ្រោះយោបល់ជាមួយសមាជិកបណ្តាញរបស់ខ្លួន និង/ឬជាមួយ NGOs ដែលកំពុងធ្វើការនៅក្នុងវិស័យ ឬបញ្ហាដូចគ្នា។ សេចក្តីថ្លែងការណ៍រៀបចំដោយ NGOs តាមវិស័យត្រូវបានសម្របសម្រួលដោយ NGO Forum, CCC, និង MEDi-CAM ។ បន្ថែមលើសេចក្តីប្រកាសជាលាយល័ក្ខអក្សររបស់ NGOs ដោយបានចូលរួមក្នុងកិច្ចប្រជុំ GDCC តំណាងអង្គការមិនមែនរដ្ឋាភិបាលអាចលើកបញ្ហានៃសេចក្តីថ្លែងការណ៍នេះនៅក្នុងកិច្ចប្រជុំផ្តល់នូវព័ត៌មានលំអិតបន្ថែមអំពីបញ្ហាទាំងនេះ ឬលើកឡើងនូវបញ្ហាសំខាន់ៗដែលសមនឹងទទួលបាននូវការយកចិត្តទុកដាក់និងជាប្រយោជន៍ដល់ការពិភាក្សានៃកិច្ចប្រជុំនោះ។ រាល់ការលើកឡើងនេះ ក៏ត្រូវពាក់ព័ន្ធជាមួយនឹងរបៀបវារៈនៃកិច្ចប្រជុំផងដែរ។ ដើម្បីធានាឱ្យមានការរៀបចំប្រកបដោយប្រសិទ្ធភាព សេចក្តីថ្លែងការណ៍ដោយអង្គការមិនមែនរដ្ឋាភិបាលតាម

វិស័យគប្បីត្រូវបញ្ចប់យ៉ាងហោចណាស់ពីរសប្តាហ៍មុនពេលកិច្ចប្រជុំ GDCC ដើម្បីអាចបោះពុម្ព និងចែកចាយយ៉ាងហោចណាស់មួយសប្តាហ៍មុនថ្ងៃប្រជុំ ។

៣) ចំពោះកិច្ចប្រជុំកម្រិតខ្ពស់នៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលរៀបចំជា " ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះការអភិវឌ្ឍកម្ពុជាសម្រាប់កិច្ចប្រជុំ CDCF " និង "សេចក្តីថ្លែងការណ៍សង្ខេបរបស់អង្គការមិនមែនរដ្ឋាភិបាលសំរាប់កិច្ចប្រជុំ CDCF លើបញ្ហាអាទិភាពចន្លោះពេលពីកិច្ចប្រជុំ CDCF មួយទៅកាន់កិច្ច CDCF មួយទៀត " ដែលគូសបញ្ជាក់បញ្ហាសំខាន់បំផុត និងបញ្ហាពាក់ព័ន្ធនានាតាមរយៈឯកសារពិស្តារស្តីពីជំហររបស់ NGO ។ ឯកសារស្តីពីជំហរនីមួយៗត្រូវបានរៀបរៀងដោយ " អង្គការមិនមែនរដ្ឋាភិបាល / ក្រុមតាមវិស័យ" ដែលទទួលខុសត្រូវចំពោះការរៀបចំឯកសារ ស្តីពីជំហររៀងៗខ្លួនដោយផ្អែកលើមូលដ្ឋាននៃការពិគ្រោះយោបល់ជាមួយសមាជិក (បណ្តាញ) របស់ខ្លួន និងជាមួយ NGOs ដទៃទៀតនៅក្នុងវិស័យដូចគ្នាក៏ដូចជាជាមួយក្រុមសហគមន៍ពាក់ព័ន្ធតាមការចាំបាច់ ។ ការណ៍នេះ គឺដើម្បីធានាឱ្យបាននូវសម្លេងរួមក្នុងចំណោមសង្គមស៊ីវិល និងធ្វើការកំណត់រកបញ្ហាអភិវឌ្ឍន៍អាទិភាពសំខាន់ៗ និងបញ្ហាប្រឈមជារួមនៅក្នុងវិស័យនោះ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីថ្លែងការណ៍រួម (ជាសង្ខេបលើបញ្ហាអន្តរវិស័យ)របស់ NGO ។ ជាមួយគ្នានេះ NGOs តំណាងទាំងបី ( NGO Forum, CCC និង MEDiCAM ) សម្របសម្រួលដំណើរការនេះ និងត្រួតពិនិត្យគុណភាពនៃឯកសារស្តីជំហរតាមវិស័យ ។ សេចក្តីថ្លែងការណ៍នេះ គប្បីមានលក្ខណៈស្ថាបនាមានភស្តុតាងច្បាស់លាស់ ឬមានលក្ខណៈវិទ្យាសាស្ត្រព្រមទាំងលក្ខណៈវិជ្ជាជីវៈ ដើម្បីឱ្យសេចក្តីថ្លែងការណ៍នោះអាចរួមចំណែកចំពោះការពិភាក្សាប្រកបដោយផ្លែផ្កាក្នុងការទទួលបានដំណោះស្រាយល្អប្រសើរសម្រាប់ទាំងអស់គ្នា។ ក្រោយពេលពិនិត្យផ្ទៀងផ្ទាត់ដើម្បីធានាថាឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលមានគុណភាពល្អ ឯកសារនេះនឹងត្រូវបានបោះពុម្ព ផ្សព្វផ្សាយ និងដាក់ជូនរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ មុននឹងកិច្ចប្រជុំ CDCF ។ ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ឯកសារនេះប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលា ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យគប្បីត្រូវបញ្ចប់យ៉ាងហោចណាស់មួយខែ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំ CDCF ដើម្បីធ្វើការបោះពុម្ព និងចែកចាយឯកសារទាំងនោះទៅដល់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដៃគូអភិវឌ្ឍន៍ឱ្យបានពីរសប្តាហ៍មុនថ្ងៃប្រជុំ ។




*ឯកសារស្តីពីជំហររបស់ NGO ចំពោះការអភិវឌ្ឍរបស់កម្ពុជាសម្រាប់កិច្ចប្រជុំ CDCF*



*សេចក្តីថ្លែងការណ៍របស់ NGO ស្តីពីការតាមដានសូចនាករតាមដានរួមរបស់ CDCF សម្រាប់កិច្ចប្រជុំ GDCC*

សេចក្តីថ្លែងការណ៍និងឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាល[១៤]ដែលបានរៀបចំតាមរយៈ: ការពិគ្រោះយោបល់ជាមួយសមាជិក (បណ្តាញ) និង/ ក្រុម គប្បីគូសបញ្ជាក់បញ្ហាសំខាន់ៗនានានៅក្នុងវិស័យឬការងារផ្ទាល់របស់ពួកគេផ្សារភ្ជាប់ជាមួយនឹងដំណោះស្រាយ/អនុសាសន៍ដែលអាចមាន ដើម្បីដាក់ជូនរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិចារណា និងចាត់វិធានការណ៍តាមជាក់ស្តែង។ សេចក្តីថ្លែងការណ៍ ឬឯកសារជំហររបស់អង្គការមិនមែនរដ្ឋាភិបាលនីមួយៗត្រូវបានផ្តល់ឱ្យ NGO Forum សម្រាប់ចងក្រង និងបោះពុម្ពផ្សាយ។

[១៤] ចំពោះសេចក្តីប្រកាសរបស់ NGO ស្តីពីការតាមដានសូចនាកររបស់ CDCF សម្រាប់កិច្ចប្រជុំ GDCC និងឯកសារជំហររបស់ NGO ស្តីពីការអភិវឌ្ឍន៍របស់កម្ពុជាសម្រាប់កិច្ចប្រជុំ CDCF ជាភាសាខ្មែរ និងភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័ររបស់យើងខ្ញុំតាមអាស័យដ្ឋាន www. ngoforum.org.kh ឬចូលទៅតាមអាស័យដ្ឋាននេះ http://www.ngoforum.org.kh/eng/core/en-publications.php?docs=dppdoc ។ នៅក្នុងដំណើរការនីមួយៗនៃការរៀបចំសេចក្តីប្រកាសរបស់ NGOs និងឯកសារជំហររបស់ NGO វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយ CCC, MEDiCAM និង NGOsតាមវិស័យ រៀបចំ និងបញ្ជូនគំរូ ឬទម្រង់សម្រាប់ឱ្យ NGOs តាមវិស័យទាំងអស់ ដើម្បីធានាឱ្យមានសង្គតិភាពចំពោះសេចក្តីប្រកាស និងឯកសារស្តីពីជំហរនានា។

☞ **ហេតុអ្វីបានជាអង្គការមិនមែនរដ្ឋាភិបាល គប្បីសរសេរសេចក្តីថ្លែងការណ៍ត្រួតពិនិត្យតាមដាន/ឯកសារស្តីពីគោលជំហរសំរាប់កិច្ចប្រជុំ GDCC និង CDCF?**

ជាមួយនឹងវត្តមាននៃយន្តការសម្របសម្រួលការប្រើប្រាស់យន្តការទាំងនេះឱ្យអស់លទ្ធភាព គឺកាន់តែមានលក្ខណៈសមស្របក្នុងការដោះស្រាយបញ្ហាអភិវឌ្ឍន៍ និងបញ្ហាប្រឈមមុនពេលដែលវិធានការណ៍ដទៃទៀតត្រូវអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ដែលអាចមានឥទ្ធិពលជាអវិជ្ជមានមកលើយន្តការពិភាក្សា និងការចូលរួមរបស់ពួកគេក្នុងពេលអនាគត។ ជាមួយនឹងឱកាស ដែលបានផ្តល់ឱ្យតំណាង NGOs/CSO ក្នុងការចូលរួមក្នុងកិច្ចប្រជុំ TWG ពួកគេអាចលើកឡើងនូវបញ្ហានានាដែលទាក់ទងនឹងផលប៉ះពាល់នៃការអភិវឌ្ឍន៍ និងបញ្ហាប្រឈមនានា ដើម្បីពិភាក្សាលើការអនុវត្តផែនការតាមវិស័យ/តាមប្រធានបទ ឬក៏ពិភាក្សាលើកម្មវិធីកំណែទម្រង់និងការអនុវត្ត JMI។ យ៉ាងហោចណាស់ បញ្ហា និងបញ្ហាប្រឈមមួយចំនួនអាចទទួលបានជោគជ័យដោយលក្ខណៈបច្ចេកទេសតាមរយៈការសម្របសម្រួល និងការពិភាក្សានៅកម្រិត TWG។

ជាគោលការណ៍ និងការអនុវត្តជាក់ស្តែង បញ្ហាដែលមិនមានវឌ្ឍនភាព ឬមិនត្រូវបានដោះស្រាយនៅកម្រិត TWG អាចត្រូវបានលើកយកទៅពិភាក្សានិងដោះស្រាយនៅក្នុងកិច្ចប្រជុំ GDCC និង CDCF។ នៅក្នុងកិច្ចប្រជុំ GDCC និងCDCF ប្រធានអង្គប្រជុំអាចតម្រូវឱ្យមន្ត្រីក្រសួង/ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មកពី TWG នីមួយៗ មានគណនេយ្យភាពចំពោះកង្វះវឌ្ឍនភាព ឬកង្វះការសម្របសម្រួលរបស់ពួកគេ។ ត្រង់នេះជាចំណុចដែល NGOs អាចឆ្លៀតឱកាសក្នុងការស្នើឱ្យរាជរដ្ឋាភិបាល និងម្ចាស់ជំនួយមានគណនេយ្យភាពចំពោះកិច្ចការនិងការសន្យានានា ដូចជា កង្វះការសម្របសម្រួល ឬភាពយឺតយ៉ាវនៃវឌ្ឍនភាពនៅក្នុងកម្មវិធីកំណែទម្រង់ ឬនៅក្នុងការអនុវត្តផែនការតាមវិស័យ ឬក្នុងការអនុវត្ត JMIs ក៏ដូចជាការសម្របសម្រួលទឹកប្រាក់ជំនួយ និងការបន្ស៊ីហិរញ្ញប្បទានជំនួយទៅនឹងផែនការតាមវិស័យ ឬអាទិភាពអភិវឌ្ឍន៍នៅកម្ពុជាដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ប្រសិនបើបញ្ហា ឬបញ្ហាប្រឈមទាំងឡាយដែលលើកឡើងដោយតំណាងនានារបស់ NGO/CSO មិនអាចត្រូវបានដោះស្រាយនៅកម្រិត TWG ទេនោះ NGOs នៅមានឱកាសក្នុងការលើកឡើងនូវបញ្ហាទាំងនោះជាថ្មីម្តងទៀត តាមរយៈការសរសេរសេចក្តីប្រកាស និងឯកសារស្តីពីជំហររបស់ NGO (ក្នុងទម្រង់នៃរបាយការណ៍តាមដាន) ទៅកាន់កិច្ចប្រជុំ GDCC និង CDCF ដែលជាពេលមួយសំរាប់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជួបជុំគ្នាដើម្បីពិភាក្សា និងដោះស្រាយបញ្ហាលើរបៀបវារៈអាទិភាពនានានៃកិច្ចប្រជុំ។ កិច្ចប្រជុំ GDCC និង CDCF ជាការពិភាក្សាកម្រិតខ្ពស់ជាង TWG ដែលបញ្ហាប្រឈម

រឺបញ្ហានានាអាចត្រូវបានពិភាក្សាដើម្បីស្វែងរកដំណោះស្រាយ ហើយវិធីសាស្ត្រឬអភិក្រមដោះស្រាយទាំងឡាយត្រូវបានពិចារណាក្នុងអង្គប្រជុំទាំងនោះ។ នៅដំណាក់កាលនេះ ប្រធានអង្គប្រជុំអាចមានឥទ្ធិពលក្នុងការសម្រេចចិត្តចំពោះវិធានការអនាគតដែលត្រូវដោះស្រាយដោយ TWG ដែលពាក់ព័ន្ធ។ ឧទាហរណ៍ នៅក្នុងកិច្ចប្រជុំ GDCC លើកទី ១៨ កាលពីខែមេសា ឆ្នាំ២០១១ ដៃគូអភិវឌ្ឍន៍ និង NGO Forum បានបង្ហាញអំពីកង្វល់នៅក្នុងកំណត់សំគាល់ និងសេចក្តីថ្លែងការណ៍របស់ខ្លួនចំពោះរាជរដ្ឋាភិបាលទាក់ទងនឹងភាពយឺតយ៉ាវនៃវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP)។ ជាលទ្ធផល ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចូលរួម និងដឹកនាំកិច្ចប្រជុំ TWG-PFM កាលពីខែកក្កដា ឆ្នាំ២០១១ និងបានលើកឡើងពីបញ្ហានេះដើម្បីជំរុញវឌ្ឍនភាពនៃ PFMRP បន្ថែមទៀត។

ជាងនេះទៅទៀត អង្គការមិនមែនរដ្ឋាភិបាលអាចប្រើសេចក្តីថ្លែងការណ៍ និងឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីតាមដានលើសំណើ និងអនុសាសន៍របស់ខ្លួន ដែលបានសរសេរនៅក្នុងរបាយការណ៍ទាំងពីរនេះ ជាមួយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ថាតើរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នឹងឆ្លើយតបចំពោះសំណើដែលបានលើកឡើង នៅក្នុងសេចក្តីថ្លែងការណ៍/ឯកសារស្តីពីជំហរដែរ ឬយ៉ាងណានៅក្នុងការអនុវត្តជាក់ស្តែង។

# ៦ ការត្រៀមខ្លួនរបស់ NGO សម្រាប់ការចូលរួមជាយុទ្ធសាស្ត្រនៅក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF

ដើម្បីត្រៀមលក្ខណៈឱ្យបានល្អ ការណែនាំ (roadmap) សម្រាប់ការត្រៀមរៀបចំឯកសារគោលជំហរ និងសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលសំរាប់ដាក់ជូនកិច្ចប្រជុំ CDCF និង GDCC ត្រូវបានរៀបចំឡើងដើម្បីជំរាបជូនអំពីជំណាក់កាលសំខាន់ៗនៃដំណើរការរៀបចំឯកសារជាមួយនឹងរយៈពេលឱសានវាទជាក់លាក់។ ការណែនាំ ក៏ជំរាបជូនផងដែរនូវការចែករំលែកការទទួលខុសត្រូវក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ និងអង្គការតំណាង និងសម្របសម្រួលទាំងបី CCC, MEDiCAM និង NGO Forum ។ ជាធម្មតា ការណែនាំនេះ ត្រូវរៀបចំដោយ NGO Forum ដោយមានការប្រឹក្សាយោបល់ជាមួយអង្គការ CCC និង MEDiCAM ហើយត្រូវយកទៅពិភាក្សាជាមួយតំណាងអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទាំងអស់នៅក្នុង កិច្ចប្រជុំវេទិកាបញ្ហាអភិវឌ្ឍន៍ (Development Issues Forum “DIF”) ដែលរៀបចំដោយ NGO Forum សហការជាមួយ CCC និង **MEDiCAM** ។

នាយកប្រតិបត្តិនៃអង្គការសមាជិកភាពនៃCCC, MEDiCAM និង NGO Forum តែងតែចូលរួមជាតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ទោះបីជាយ៉ាងណាក៏ដោយ តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ អាចត្រូវបានជ្រើសរើសពីអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យផ្សេងទៀត តាមរយៈសមាជិក DIF ដែលអាស្រ័យទៅលើបញ្ហាអាទិភាព ឬអន្តរវិស័យដែលត្រូវលើកនៅក្នុងកិច្ចប្រជុំទាំងនេះ។ តំណាងទាំងនេះ ត្រៀមលក្ខណៈរួមគ្នារួចជាស្រេចមុននឹងចូលរួមកិច្ចប្រជុំ CDCF ។ ជាទូទៅ នាយកប្រតិបត្តិនៃអង្គការ CCC MEDiCAM និង NGO Forum តែងតែចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាស GDCC ដើម្បីធានាបន្តនូវភាពជាតំណាង និងលំហូរព័ត៌មាន និងកិច្ចអន្តរាគមន៍នានាដែលចាំបាច់នៅក្នុងកិច្ចប្រជុំ។ ដើម្បីធានានូវភាពជាតំណាងប្រកបដោយប្រសិទ្ធិភាព តំណាងអង្គការមិនមែនរដ្ឋាភិបាលគប្បីមានជំនាញភាសាអង់គ្លេសល្អ និងមានបទពិសោធន៍ដែលពាក់ព័ន្ធនឹងបញ្ហាអាទិភាព ឬអន្តរវិស័យដែលត្រូវលើកឡើងនៅក្នុងកិច្ចប្រជុំទាំងពីរ។

គេសង្កេតឃើញថា ដើម្បីធានាឱ្យអង្គការមិនមែនរដ្ឋាភិបាលត្រៀមលក្ខណៈបានល្អ និងចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងយន្តការនៃកិច្ចប្រជុំ CDCF GDCC និង TWGs វាជាប្រការសំខាន់ដែល:

- អង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមគប្បីមានទំនាក់ទំនងល្អ និងសម្របសម្រួលសមាជិករបស់ខ្លួនឱ្យបានល្អនៅតាមវិស័យ ដើម្បីមានជាទស្សនៈរួមមួយសំរាប់ជាតំណាងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យនោះ ។
- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាល គប្បីមានការយល់ដឹងច្បាស់លាស់អំពីវិស័យរបស់ខ្លួន និងអំពីផែនការរបស់រាជរដ្ឋាភិបាល និងការជួយគាំទ្ររបស់ដៃគូអភិវឌ្ឍន៍តាមរយៈក្រុមការងារបច្ចេកទេសនិងទំនាក់ទំនងការងារផ្សេងៗទៀតជាមួយនឹងក្រសួង ឬស្ថាប័នសាមីរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ។
- តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំទាំងនេះ គប្បីរក្សាការចូលរួមរបស់ខ្លួនអោយបានទៀងទាត់ ដើម្បីកសាងទំនាក់ទំនងជាមួយសមាជិកផ្សេងទៀតនៃក្រុមការងារបច្ចេកទេស ។
- ដោយសារកិច្ចប្រជុំភាគច្រើនត្រូវបានពិភាក្សាជាភាសាអង់គ្លេស តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលគប្បីមានជំនាញភាសាអង់គ្លេសល្អ ដើម្បីបកស្រាយឱ្យបានច្បាស់លាស់នូវទស្សនៈរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យនិមួយៗ ។

# ៧ តើអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលវាស់ស្ទង់ប្រសិទ្ធភាព ឬលទ្ធផលនៃការចូលរួមរបស់ខ្លួនយ៉ាងដូចម្តេចនៅក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF ?

សំណួរនេះ ត្រូវបានចោទសួរជារឿយៗដោយអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យជាច្រើនដែលរួមមានបណ្តា NGOs ដែលបានចូលរួមរួចមកហើយនៅក្នុងកិច្ចប្រជុំ TWGs GDCC និង CDCF ។ ចំពោះកិច្ចប្រជុំ TWGs តំណាងអង្គការមិនមែនរដ្ឋាភិបាលម្នាក់ (ឬច្រើននាក់) ត្រូវមានលទ្ធភាពវាស់ស្ទង់ប្រសិទ្ធ–ភាព និងលទ្ធផលនៃការចូលរួមរបស់ពួកគេក្នុងការពិភាក្សាអំពីគោលនយោបាយនៅកម្រិតនោះដោយសារតែពួកគេកំពុងធ្វើការនៅក្នុងផ្នែកដែលពាក់ព័ន្ធនានាស្រាប់ ។ ចំពោះកិច្ចប្រជុំ GDCC និង CDCF វិញ ការវាស់ស្ទង់ពីវិស័យដែល NGOs បាន និងកំពុងធ្វើការនៅកម្រិត TWG គឺមិនសមស្របឡើយ ព្រោះថារបាយការណ៍តាមដាន និងឯកសារស្តីពីជំហររបស់ពួកគេចំពោះការអនុវត្ត JMIs និង NSDP មានឫសគល់យ៉ាងជ្រៅនៅក្នុងការសម្របសម្រួលបច្ចេកទេសនៅកម្រិត TWG ។ អ្វីដែលត្រូវវាស់ស្ទង់ពីកិច្ចប្រជុំ GDCC និង CDCF គឺបញ្ហាសំខាន់ៗរបស់ពួកគេដែលបានលើកឡើង ឬដែលបានពិចារណានៅក្នុងអំឡុងពេលប្រជុំ និងការដែលអ្នករៀបចំគោលនយោបាយឬអ្នកធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានឆ្លើយតប ឬបានបង្ហាញការប្តេជ្ញាចិត្តដើម្បីដោះស្រាយ ឬដំណោះស្រាយណាមួយ ។ គេអាចមើលឃើញការណ៍នេះតាមរយៈរបាយការណ៍ និងសេចក្តីថ្លែងការណ៍[១៥] ឬកំណត់សំគាល់ពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងកិច្ចប្រជុំ GDCC និង CDCF ហើយ និងអាចពិនិត្យឃើញតាមរយៈការធ្វើសង្ខេបដោយតំណាង NGO អំពីលទ្ធផលនៃកិច្ចប្រជុំទាំងពីរ ។ ដើម្បីធានាថាការប្តេជ្ញាចិត្ត ឬការឆ្លើយតបទាំងនោះអាចត្រូវបានគេទទួលយក NGOs អាចតាមពិនិត្យបន្តជាមួយ TWGs ដែលពាក់ព័ន្ធនានា ដោយផ្អែកលើមូលដ្ឋាននៃរបាយការណ៍តាមដានរបស់ខ្លួន ដែលបានដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍ និងឯកសារគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលដែលតាមដានសូចនាករតាមដានរួម និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការឆ្លើយតបនានានៅក្នុងកិច្ចប្រជុំ GDCC និងCDCF ។

---

[១៥] ចំពោះរបាយការណ៍នៃកិច្ចប្រជុំនានា របាយការណ៍វឌ្ឍនភាព និងកំណត់សំគាល់នានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍រៀបរៀងដោយ TWG និងឯកសារដទៃ សូមចូលទៅកាន់គេហទំព័ររបស់ CRDB/CDC ។

បន្ថែមពីលើនេះ ពួកគាត់ក៏អាចធ្វើសកម្មភាពសវនកម្មសង្គមនៅកម្រិតមូលដ្ឋានដើម្បីពិនិត្យ និងតាមដានមើលថា តើមានការប្រែក្លាយគោលនយោបាយនានា ឬការសន្យានានាទៅជាការអនុវត្តជាក់ស្តែងឬទេ។ សវនកម្មសង្គមសំដៅដល់ការវាយតម្លៃឯករាជ្យ និងមានការចូលរួមពីសហគមន៍ឬប្រជាជនចំពោះសមិទ្ធិកម្ម (លទ្ធផលនៃការអនុវត្តការងារ) នៃស្ថាប័នសាធារណៈ ឬកម្មវិធី/ផែនការ ឬគម្រោងណាមួយដែលមានការចូលរួមពីក្រុមផ្សេងៗគ្នា។ ដោយផ្អែកលើបទពិសោធន៍របស់ NGOs នៅប្រទេសឥណ្ឌា សវនកម្មសង្គម[១៦]មានប្រាំដំណាក់កាល ដូចជា ការប្រមូលព័ត៌មាន ការប្រៀបធៀបនិងការវិភាគ ព័ត៌មាន ការចែករំលែកព័ត៌មាន ការធ្វើសវនាការជាសាធារណៈ (Public Hearing )និងការតាមពិនិត្យបន្តចំពោះសវនាការជាសាធារណៈនៅក្នុងការអនុវត្តន៍។ គំរូនេះក៏ត្រូវបានអនុវត្តដូចគ្នាដោយ NGOs នៅកម្ពុជា រួមមានអង្គការ MEDiCAM ជាដើម។ អង្គការនេះរៀបចំវេទិកាសុខភាពសហគមន៍ប្រចាំតំបន់ដោយមានការចូលរួមពីមន្ត្រីរដ្ឋាភិបាលនៅក្រសួងសុខាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជននៅសហគមន៍ (អ្នកប្រើប្រាស់សេវាកម្មសុខាភិបាល)។

[១៦] ចំពោះការពន្យល់លំអិត សូមទាក់ទង NGO Forum តាមអាស័យដ្ឋាន ngoforum@ngoforum.org.kh ។

# ឧបសម្ព័ន្ធ៖ ព័ត៌មានទំនាក់ទំនងនៃតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងក្រុមការងារបច្ចេកទេស (TWGs)

## ១. ក្រុមការងារបច្ចេកទេស កសិកម្ម និងធនធានទឹក

**មជ្ឈមណ្ឌលកម្ពុជា សំរាប់ការសិក្សា និងអភិវឌ្ឍន៏កសិកម្ម (CEDAC)**

ទូរស័ព្ទលេខ៖ ៨៥៥-១២ ៨៦៩ ៤៤៣

អ៊ីម៉ែល៖ makarady@cedac.org.kh

វែបសាយ៖ www.cedac.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ ទឹកល្អក់ ១ ខ័ណ្ឌ ទួលគោក ភ្នំពេញ

## ២. ក្រុមការងារបច្ចេកទេស វិមជ្ឈការ និង វិសហមជ្ឈការ

**ស្តារ កម្ពុជា (STAR Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១១ ៦១២

ទូរសារលេខ៖ ៨៥៥-២៣ ២១១ ៨១២

អ៊ីម៉ែល៖ star-vac@starkampuchea.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៦៧ ផ្លូវ ១២៣ រឺ ៤៦៨ សង្កាត់ ទួលទំពូង ១ ភ្នំពេញ កម្ពុជា

## ៣. ក្រុមការងារបច្ចេកទេសអប់រំ

**ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល (NEP)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២២៤ ៧៧៤

អ៊ីម៉ែល៖info@nepcambodia.org រឺ dir@nepcamobdia.org

វែបសាយ៖ www.nepcambodia.org

អាសយដ្ឋាន៖ ផ្ទះលេខ ១១អេ ផ្លូវ ២៤៨ សង្កាត់ វាលវង់ ខ័ណ្ឌ ប្រាំពីរមករា ភ្នំពេញ

## ៤. ក្រុមការងារបច្ចេកទេសជលផល

**សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)**

ទូរស័ព្ទលេខ៖ ៨៥៥-៩៩២ ០៤៤

ទូរសារលេខ៖ ៨៥៥-៩៩២ ០៤៤

អ៊ីម៉េល៖ fact@online.com.kh

វែបសាយ៖ www.fact.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ២១៥ ផ្លូវ ១៥០ សង្កាត់ ទឹកល្អក់ ខណ្ឌ ទួលគោក ភ្នំពេញ

## ៥. ក្រុមការងារបច្ចេកទេស-សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១៤ ៤២៩

ទូរសារលេខ៖ ៨៥៥-២៣ ៩៩៤ ០៦៣

អ៊ីម៉េល៖ ngoforum@ngoforum.org.kh

វែបសាយ៖ www.ngoforum.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

**ការីតាស កម្ពុជា (Caritas Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១០ ៧៥៧, ២១៣ ៥២៩

ទូរសារលេខ៖ ៨៥៥-២៣ ២១៦ ២៥៨

អ៊ីម៉េល៖ caritas@caritascambodia.org

វែបសាយ៖ http://caritascambodia.org

អាសយដ្ឋាន៖ ផ្ទះលេខ ៤៧ ផ្លូវ ១៩៨ សង្កាត់ បឹងប្រលិត ខណ្ឌ ៧ មករា ភ្នំពេញ

## ៦. ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១៤ ៤២៩

ទូរសារលេខ៖ ៨៥៥-២៣ ៩៩៤ ០៦៣

អ៊ីម៉េល៖ ngoforum@ngoforum.org.kh

វែបសាយ៖ www.ngoforum.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

### ៧. ក្រុមការងារបច្ចេកទេស-យេនឌ័រ

**អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C)**

ទូរស័ព្ទលេខ: ៨៥៥-២៣ ២១៥ ១៣៧

ទូរសារលេខ: ៨៥៥-២៣ ៩៩៦ ៩៣៤

អ៊ីម៉ែល: gad@online.com.kh

វេបសាយ: www.gad.org.kh

អាសយដ្ឋាន: ផ្ទះលេខ ៨៩ ផ្លូវ ២៨៨ សង្កាត់ អូឡាំពិក ខ័ណ្ឌ ចំការមន ភ្នំពេញ ប្រអប់សំបុត្រលេខ ២៦៨៤

### ៨. ក្រុមការងារបច្ចេកទេស សុខាភិបាល

**អង្គការម៉េឌីខាំ (MEDiCAM)**

ទូរស័ព្ទលេខ: ៨៥៥-២៣ ៨៨០ ២៩១

ទូរសារលេខ: ៨៥៥-២៣ ៨៨០ ២៩២

អ៊ីម៉ែល: info@medicam-cambodia.org

វេបសាយ: www.medicam-cambodia.org

អាសយដ្ឋាន: ផ្ទះលេខ ៤ ផ្លូវ ៥២២ សង្កាត់ បឹងកក ១ ខ័ណ្ឌ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៦៦

### ៩. ក្រុមការងារបច្ចេកទេស-មេរោគអេដស៍ និងជម្ងឺអេដស៍

**អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍ (KHANA)**

ទូរស័ព្ទលេខ: ៨៥៥-២៣ ២១១ ៥០៥

ទូរសារលេខ: ៨៥៥-២៣ ៤១៤ ០៤៩

វេបសាយ: http://www.khana.org.kh

អាសយដ្ឋាន: ផ្ទះលេខ ៣៣ ផ្លូវ ៧១ ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ២៣១១

វេបសាយ: http://www.khana.org.kh

### ១០. ក្រុមការងារបច្ចេកទេស-ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់

មិនមានតំណាងអង្គការមិនមែនរដ្ឋាភិបាល

## ១១. ក្រុមការងារបច្ចេកទេស ដីធ្លី

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១៤ ៤២៩

ទូរសារលេខ៖ ៨៥៥-២៣ ៩៩៤ ០៦៣

អ៊ីមែល៖ ngoforum@ngoforum.org.kh

វេបសាយ៖ www.ngoforum.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

## ១២. ក្រុមការងារបច្ចេកទេស កំណែទម្រង់ច្បាប់ និង តុលាការ

**ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ៨៨៣ ៩១៤

ទូរសារលេខ៖ ៨៥៥-២៣ ៨៨០ ៩១៤

អ៊ីមែល៖ lac@lac.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៥១ ផ្លូវ ៦០៨ សង្កាត់ បឹងកក ២ ខណ្ឌ ទួលគោក ភ្នំពេញ
ប្រអប់សំបុត្រលេខ ១១៩៧

## ១៣. ក្រុមការងារបច្ចេកទេស-សកម្មភាព មីន

**អង្គការ ហេឡូ ត្រាស កម្ពុជា (The HALO Trust Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥-៦៣ ៣៨០ ១៧៨
៨៥៥-១២ ៨០៨ ៦៣០

អ៊ីមែល៖ mail@halocambodia.org

វេបសាយ៖ www.halocambodia.org

អាសយដ្ឋាន៖ ភូមិជ័យ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប

## ១៤. ក្រុមការងារបច្ចេកទេស-ភាពជាដៃគូរ និង សុខដុមនីយកម្ម

**គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)**

ទូរស័ព្ទលេខ៖ ៨៥៥-២៣ ២១៤ ១៥២ រឺ ២១៦ ០០៩

ទូរសារលេខ៖ ៨៥៥-២៣ ២១៩ ០០៩

អ៊ីមែល៖ info@ccc-cambodia.org

វែបសាយ: www.ccc-cambodia.org
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

**អង្គការមេឌីខាំ (MEDiCAM)**
ទូរស័ព្ទលេខ : ៨៥៥-២៣ ៨៨០ ២៩១
ទូរសារលេខ: ៨៥៥-២៣ ៨៨០ ២៩២
អ៊ីម៉ែល: info@medicam-cambodia.org
វែបសាយ: www.medicam-cambodia.org
អាសយដ្ឋាន: ផ្ទះលេខ ៤ ផ្លូវ ៥២២ សង្កាត់ បឹងកក ១ ខណ្ឌ ទួលគោក ភ្នំពេញ
ប្រអប់សំបុត្រលេខ ១១៦៦

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**
ទូរស័ព្ទលេខ: ៨៥៥-២៣ ២១៤ ៤២៩
ទូរសារលេខ: ៨៥៥-២៣ ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
វែបសាយ: www.ngoforum.org.kh
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

## ១៥. ក្រុមការងារបច្ចេកទេស-ផែនការ និងការកាត់បន្ថយភាពក្រីក្រ

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia )**
ទូរស័ព្ទលេខ : ៨៥៥-២៣ ២១៤ ៤២៩
ទូរសារលេខ: ៨៥៥-២៣ ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
វែបសាយ: www.ngoforum.org.kh
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

## ១៦. ក្រុមការងារបច្ចេកទេស-ការអភិវឌ្ឍន៍វិស័យឯកជន

មិនមានតំណាងអង្គការមិនមែនរដ្ឋាភិបាល

### ១៧. ក្រុមការងារបច្ចេកទេស–កំណែទម្រង់រដ្ឋបាលសាធារណៈ

មិនមានតំណាងអង្គការមិនមែនរដ្ឋាភិបាល

### ១៨. ក្រុមការងារបច្ចេកទេស–ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (The NGO Forum on Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥–២៣ ២១៤ ៤២៩

ទូរសារលេខ៖ ៨៥៥–២៣ ៩៩៤ ០៦៣

អ៊ីម៉េល៖ ngoforum@ngoforum.org.kh

វែបសាយ៖ www.ngoforum.org.kh

អាសយដ្ឋាន៖ ផ្ទះលេខ ៩–១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន ភ្នំពេញ

### ១៩. ក្រុមការងារបច្ចេកទេស–ផ្គត់ផ្គង់ទឹកជនបទ អនាម័យ និងការរស់នៅស្អាត

**អង្គការអភិវឌ្ឍន៍ធនធានអន្តរជាតិ កម្ពុជា (Resource Development International-Cambodia)**

ទូរស័ព្ទលេខ៖ ៨៥៥–១២ ២០០ ២៣៥

៨៥៥–១៧ ៧៧៨ ៥៣៣

អ៊ីម៉េល៖ info@rdic.org

វែបសាយ៖ http://www.rdic.org/

អាសយដ្ឋាន៖ ភូមិព្រែកធំ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល

## ព័ត៌មានសម្រាប់ទំនាក់ទំនង ៖

*គម្រោងគោលនយោបាយអភិវឌ្ឍន៍នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ផ្តល់ការគាំទ្រក្នុងការសម្របសម្រួលជូនអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយដែលចូលរួមយ៉ាងសកម្មក្នុងយន្តការទាំងនេះ។ ដោយយោងតាមបទពិសោធន៍ ការអង្កេតដែលមានលក្ខណៈវិទ្យាសាស្ត្រ និងចំណេះដឹងជាក់ស្តែងស្តីពីស្ថានភាពអភិវឌ្ឍន៍នៅកម្រិតមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលរួមគ្នាអាចមានឥទ្ធិពលធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ភាពប្រសើរឡើងរបស់ប្រទេសកម្ពុជា តាមរយៈការចូលរួមជាវិជ្ជមានទៅក្នុងការរៀបចំ និងអនុវត្តគោលនយោបាយដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋជាពិសេសប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ សំរាប់ព័ត៌មានបន្ថែមអំពីបញ្ហានានាដែលបានលើកឡើងនៅក្នុងសៀវភៅណែនាំនេះ សូមទាក់ទងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមអាស័យដ្ឋានផ្តល់ជូនខាងក្រោមនេះ។*

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
*The NGO Forum on Cambodia*
**ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង**
*Working Together for Positive Change*

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
គម្រោងគោលនយោបាយអភិវឌ្ឍន៍នៃកម្មវិធីបញ្ហាអភិវឌ្ឍន៍
អាសយដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ ទួលទំពូងទី ១
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ៣ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩ / ទូរសារ៖(៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉េល៖ ngoforum@ngoforum.org.kh
វែបសាយ៖www.ngoforum.org.kh
វែបសាយស្តីពីថវិកាជាតិកម្ពុជា៖www.cambodianbudget.org